J Trust Royal Bank

# លក្ខន្តិកៈប្រាក់កម្ចីទិញផ្ទះ

មានសុពលភាពចាប់ពី ខែសីហា ឆ្នាំ២០១៩

**លក្ខខណ្ឌទូទៅ (អត្ថបទបោះផ្សាយ ឆ្នាំ២០១៩)**

## តារាងមាតិកា


**កាតព្វកិច្ចរបស់យើងខ្ញុំ (ភាគីធនាគារ រឺម្ចាស់បំណុល)** ........ ៣
១. ការផ្តល់សំណុំឥណទាន ........ ៣
២. រយៈពេលនៃសំណុំឥណទាន ........ ៣
**កាតព្វកិច្ចរបស់លោក-អ្នក (ភាគីអតិថិជន រឺ កូនបំណុល)** ........ ៣
៣. ការទូទាត់សងសំណុំឥណទាន ........ ៣
៤. ការផ្តល់សំណុំឥណទាន ........ ៣
៥. ការធានាអះអាងរបស់លោកអ្នក- ........ ៤
៦. ការធានារ៉ាប់រង ........ ៦
៧. ព័ត៌មាន ........ ៦
៨. ច្បាប់បរិស្ថាន ........ ៦
៩. អត្រាការប្រាក់ប្រែប្រួល ........ ៦
១០. ការវាយតំលៃ ........ ៦
១១. ថ្លៃចំណាយដែលលោក–អ្នកត្រូវបង់ ........ ៦
១២. ចំនួនទឹកប្រាក់ដែលប្រើហួសកំរិត និង ទឹកប្រាក់ដែលមិនបានបង់តាមកាលកំណត់ ........ ៧
**ការត្រួតពិនិត្យឡើងវិញ** ........ ៨
១៣. ការត្រួតពិនិត្យឡើងវិញលើសំណុំឥណទាន ........ ៨
**ការរំលោភ ឬ ល្មើស ឬ បំពាន លើកិច្ចព្រមព្រៀង ឬ កាតព្វកិច្ច** ........ ៩
១៤. ការរំលោភលើកិច្ចព្រមព្រៀង ........ ៩
១៥. ផលវិបាកនៃការរំលោភលើកិច្ចព្រមព្រៀង ........ ១១
**ការបង់ទូទាត់** ........ ១១
១៦. ការបង់ទូទាត់ជាទូទៅ ........ ១១
១៧. គ្មានការកាត់បន្ថយពីការបង់ទូទាត់នានារបស់លោកអ្នក- ........ ១២
១៨. រូបិយប័ណ្ណខុសគ្នា ........ ១៣
**ការជូនដំណឹង** ........ ១៣
១៩. ការជូនដំណឹង ........ ១៣

**គោលការណ៍ទូទៅ**......១៤
២០. ការជួលអ្នកជំនាញ និង ទីប្រឹក្សាពិគ្រោះយោបល់......១៤
២១. ការលះបង់សិទ្ធិ......១៤
២២. រូបិយប័ណ្ណ......១៤
២៣. ការបំលែងរូបិយប័ណ្ណរបស់សំណុំឥណទាន......១៤
២៤. ការប្រែប្រួលជាគំរូវការរបស់រដ្ឋាភិបាល......១៤
២៥. ការប្រែប្រួលនៃច្បាប់......១៥
២៦. ច្បាប់ និង យុត្តាធិការ......១៥
២៧. សំណុំឥណទានដែលកំពុងមានជាធរមាន (សំណុំឥណទានដែលមានស្រាប់ ឬ បច្ចុប្បន្ន)......១៥
២៨. ការរួមបញ្ចូលគណនី......១៦
២៩. ការព្រមព្រៀងចំពោះព័ត៌មានផ្ទាល់ខ្លួន......១៦
៣០. ការព្រមព្រៀងផ្នែកហិរញ្ញវត្ថុ......១៦
**ការបកស្រាយកិច្ចព្រមព្រៀងនេះ**......១៧
៣១. អត្ថន័យរបស់ពាក្យ និង សំនួនសេចក្តី......១៧
៣២. ចំណុចផ្សេងៗ......២០
៣៣. ភាពមិនស៊ីសង្វាក់គ្នា......២២
៣៤. បញ្ញត្តិស្តីពីការបកស្រាយផ្សេងទៀត......២២

**ភាតព្វកិច្ចរបស់យើងខ្ញុំ (ភាគីធនាគារ រឺ ម្ចាស់បំណុល)**

## ១. ការផ្ដល់សំណុំឥណទាន

យើងខ្ញុំយល់ព្រមផ្ដល់ជូនលោក-អ្នកនូវសំណុំឥណទានស្របតាម រាល់ខ និង លក្ខខណ្ឌ នៃកិច្ចព្រមព្រៀងនេះ ហើយតាមរយៈនេះដែរ លោក-អ្នក ក៏យល់ព្រមទទួល និង បំពេញនូវកាតព្វកិច្ចនានា តាមខ និង លក្ខខណ្ឌ នៃកិច្ចព្រមព្រៀងនេះ។

## ២. រយៈពេលនៃសំណុំឥណទាន

យើងខ្ញុំនឹងផ្ដល់សំណុំឥណទាននីមួយៗ ទៅតាមរយៈពេលដែលបានព្រមព្រៀង លើកលែងតែះ

(ក) លោក-អ្នកបានរំលោភលើកិច្ចព្រមព្រៀង ហើយ យើងខ្ញុំប្រើប្រាស់សិទ្ធិបញ្ចប់សំណុំឥណទាន រឺ

(ខ) មានការប្រែប្រួលនៃច្បាប់ដែលរារាំងយើងខ្ញុំក្នុងការផ្ដល់សំណុំឥណទាន។

**កំណត់សំគាល់:** *លោក-អ្នកនឹងរំលោភលើកិច្ចព្រមព្រៀងនេះ បើសិនជាលោក-អ្នកមិនគោរពតាមកាតព្វកិច្ចរបស់ខ្លួនដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ។ ដើម្បីស្វែងយល់ពីអត្ថន័យ នៃការ "រំលោភ ឬ ល្មើសលើកិច្ចព្រមព្រៀង" សូមមើលប្រការ ១៤។ ដើម្បីស្វែងយល់ពីសិទ្ធិរបស់យើងខ្ញុំក្នុងករណីដែល លោក-អ្នក រំលោភ ឬ ល្មើស លើកិច្ចព្រមព្រៀង សូមមើលប្រការ ១៥។ ដើម្បីស្វែងយល់ពីសិទ្ធិរបស់យើងខ្ញុំក្នុងករណីមានការប្រែប្រួលនៃច្បាប់ដែល រារាំងយើងខ្ញុំក្នុងការផ្ដល់សំណុំឥណទានជូនដល់លោក-អ្នក សូមមើលប្រការ ២៥។*

**រយៈពេលដែលបានព្រមព្រៀង** មានន័យថាះ

(ក) បើសិនជាលិខិតផ្ដល់ឥណទានចែងអំពីកាលបរិច្ឆេទបញ្ចប់សំណុំឥណទានច្បាស់លាស់ នោះរយៈពេលគឺគិតរហូតដល់កាលបរិច្ឆេទបញ្ចប់សំណុំឥណទាន។

(ខ) បើសិនជាលិខិតផ្ដល់ឥណទានចែងថា សំណុំឥណទាននឹងត្រូវផ្ដល់ជូនយ៉ាងហោចណាស់រហូតដល់កាលបរិច្ឆេទត្រួតពិនិត្យឡើងវិញលើកក្រោយ នោះរយៈពេលគឺយ៉ាងហោចណាស់គិតរហូតដល់កាលបរិច្ឆេទត្រួតពិនិត្យឡើងវិញលើកក្រោយ។

(គ) បើសិនជាលិខិតផ្ដល់ឥណទានចែងថា សំណុំឥណទានគឺ "ត្រូវទូទាត់សងទៅតាមការទាមទារ" នោះរយៈពេលគឺគិតរហូត ដល់ពេលដែលយើងខ្ញុំទាមទារការទូទាត់សងវិញ។

**កំណត់សំគាល់:** *សំណុំឥណទានប្រភេទផ្សេងៗគ្នាអាចត្រូវផ្ដល់ជូនដោយមានរយៈពេលផ្សេងៗគ្នា។ សេចក្ដីលំអិតអំពីរយៈពេលដែលយើងខ្ញុំយល់ព្រមផ្ដល់ សំណុំឥណទានណាមួយ មានបញ្ជាក់នៅក្នុងលិខិតផ្ដល់ឥណទានរបស់យើងខ្ញុំ។*

**ភាតព្វកិច្ចរបស់លោក~អ្នក**

## ៣. ការទូទាត់សងឥណទាន

សំរាប់សំណុំឥណទាននីមួយៗ លោក-អ្នកយល់ព្រមសងប្រាក់ដែលនៅជំពាក់មកឱ្យយើងខ្ញុំ តាមកាលបរិច្ឆេទបញ្ចប់សំណុំឥណទាន។ លោក-អ្នក ក៏យល់ព្រមសងនូវប្រាក់ដែលជំពាក់ដទៃទៀត ដែលមិនទាន់បានទូទាត់ផ្អែកតាមឯកសារប្រតិបត្តិការណាមួយនៅថ្ងៃចុងក្រោយនៃ កាលបរិច្ឆេទបញ្ចប់សំណុំឥណទាន ។

## ៤. ការផ្ដល់សំណុំឥណទាន

**អ្វីដែលលោក-អ្នកត្រូវបំពេញ មុននឹងយើងខ្ញុំធ្វើការផ្ដល់ជូននូវសំណុំឥណទាន**

យើងខ្ញុំនឹងផ្ដល់ជូនលោក-អ្នក នូវសំណុំឥណទានណាមួយ លុះត្រាតែយើងខ្ញុំយល់ឃើញថា លក្ខខណ្ឌដូចខាងក្រោមត្រូវបានបំពេញយ៉ាងត្រឹមត្រូវះ

(ក) **ស្វីការ:** លោក-អ្នកបានទទួលនិងយល់ព្រមតាមលិខិតផ្ដល់ឥណទានរបស់យើងខ្ញុំ។

(ខ) **គ្មានការរំលោភលើកិច្ចព្រមព្រៀង:** គ្មានព្រឹត្តិការណ៏នៃការរំលោភលើកិច្ចព្រមព្រៀង រឺ ព្រឹត្តិការណ៏ដែលអាចក្លាយជាការរំលោភលើកិច្ចព្រមព្រៀងបានកើតឡើង និងកំពុងតែកើតមានឡើង។

(គ) **កិច្ចធានា:** យើងខ្ញុំបានទទួលនូវកិច្ចធានាដែលមានបញ្ជាក់ក្នុងលិខិតផ្ដល់ឥណទាន ព្រមទាំងឯកសារពាក់ព័ន្ធដទៃទៀត ដែលបានបំពេញ ចុះហត្ថលេខា និង ចុះបញ្ជីរួចជាស្រេច (បើសិនជាតំរូវអោយមានការចុះបញ្ជី) ដើម្បីធ្វើអោយកិច្ចធានានោះមានភាពត្រឹមត្រូវ និង អាចអនុវត្តបានស្របច្បាប់។

**កំណត់សំគាល់:** *បើសិនជាអ្នកផ្ដល់កិច្ចធានាជា ក្រុមហ៊ុនមូលធន ក្រុមហ៊ុនសហកម្មសិទ្ធិ រឺ ធ្វើជាអាណាព្យាបាល (អ្នកទទួលភារៈគ្រប់គ្រង) យើងខ្ញុំអាចទាមទារ នូវឯកសារមួយចំនួនដូចមានចែងក្នុង កថាខណ្ឌ (ង) (ច) រឺ (ឆ) (បើសិនជាមាន) ដែលទាក់ទងនឹងអ្នកផ្ដល់កិច្ចធានា។*

(ឃ) **សិទ្ធចាត់ចែងលើគណនី:** យើងបានទទួលនូវការជូនដំណឹងស្ដីពីសិទ្ធិចាត់ចែងក្នុងការប្រតិបត្តិលើគណនី។

(ង) **ក្រុមហ៊ុនមូលធន:** បើសិនលោក-អ្នកជាក្រុមហ៊ុនមូលធន ត្រូវផ្ដល់ជូនយើងខ្ញុំនូវឯកសារនានាស្ដីពីការបង្កើតក្រុមហ៊ុន និង វិញ្ញាបនប័ត្រចុះបញ្ជីក្រុមហ៊ុនមួយច្បាប់ ព្រមទាំងភស្តុតាងដែលយើងខ្ញុំយល់ថា គ្រប់គ្រាន់ដើម្បីបញ្ជាក់ថា ឯកសារទាំងនេះមានលក្ខណៈពេញលេញ ត្រឹមត្រូវ និង នៅជាធរមានទាំងស្រុងហើយមិនត្រូវបានកែប្រែ រឺលុបចោលឡើយ។

(ច) **ក្រុមហ៊ុនសហកម្មសិទ្ធិ:** បើសិនលោក-អ្នកជាក្រុមហ៊ុនសហកម្មសិទ្ធិ ត្រូវផ្តល់ជូនយើងខ្ញុំនូវកិច្ចសន្យាក្រុមហ៊ុនសហកម្មសិទ្ធិមួយច្បាប់ រឺ ឯកសារដទៃទៀត ស្តីពីការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិ ព្រមជាមួយនឹងភស្តុតាងដែលយើងខ្ញុំយល់ថា គ្រប់គ្រាន់ដើម្បីបញ្ជាក់ថា ឯកសារទាំងនេះមានលក្ខណៈ ពេញលេញ ត្រឹមត្រូវ និងនៅជាធរមានទាំងស្រុង ហើយមិនត្រូវបានកែប្រែ រឺ លុបចោលឡើយ ។

(ឆ) **អាណត្តិព្យាបាលភាព:** បើសិនលោក-អ្នកបានចុះកិច្ចព្រមព្រៀងនេះជាអាណត្តិគាហកនៃអាណត្តិព្យាបាលភាព ត្រូវផ្តល់ជូនយើងខ្ញុំនូវលិខិតសំគាល់អាណត្តិព្យាបាលភាព រឺក៏ឯកសារដទៃទៀត ស្តីពីការបង្កើតអាណត្តិព្យាបាលភាពនោះ ព្រមទាំងភស្តុតាងដែលយើងខ្ញុំយល់ថាគ្រប់គ្រាន់ដើម្បីបញ្ជាក់ថា ឯកសារទាំងនេះមានលក្ខណៈពេញលេញ ត្រឹមត្រូវ និងនៅជាធរមានទាំងស្រុង ហើយមិនត្រូវបានកែប្រែ រឺ លុបចោលឡើយ។

(ជ) **លក្ខខណ្ឌផ្សេងទៀត:** គ្រប់លក្ខខណ្ឌដទៃទៀតដើម្បីទទួលបានសំណុំឥណទានដែលមានចែងនៅក្នុងលិខិតផ្តល់ឥណទាន ត្រូវបានបំពេញទាំងអស់។

## ៥. ការធានាអះអាងរបស់លោក~អ្នក

(១) លោក-អ្នកធានាអះអាងថានៅថ្ងៃដែលលោកអ្នកផ្តល់ស្វ័ការលើលិខិតផ្តល់ឥណទានរបស់យើងខ្ញុំ សេចក្តីអះអាងលើគ្រប់ចំណុចខាងក្រោមនេះជាការពិតៈ

(ក) **ឯកសារប្រតិបត្តិការភ្ជាប់កាតព្វកិច្ច:** ឯកសារប្រតិបត្តិការនីមួយៗដែលលោក-អ្នក រឺ អ្នកផ្តល់កិច្ចធានាបានចុះហត្ថលេខា គឺភ្ជាប់កាតព្វកិច្ច លោក-អ្នក រឺ អ្នកផ្តល់កិច្ចធានា ទៅតាមអ្វីដែលមាន ហើយអាចអនុវត្តបានទៅលើ លោក-អ្នក រឺ អ្នកផ្តល់កិច្ចធានា ស្របតាមខចែងនៃឯកសារនោះ។

(ខ) **គ្មានការរំលោភលើកិច្ចព្រមព្រៀង (ឬ មិនគោរពតាមកាតព្វកិច្ច) នាពេលបច្ចុប្បន្ន:** ពុំមានការរំលោភលើកិច្ចព្រមព្រៀង (ដែលជាធាតុសំខាន់ នៅក្នុងបរិបថនៃកិច្ចព្រមព្រៀងនេះ) នៅក្រោមកិច្ចព្រមព្រៀង ការសន្យា រឺ លិខិតុបករណ៍ណាមួយ ពីខាងលោក-អ្នក រឺ អ្នកផ្តល់កិច្ចធានាឡើយ។

**កំណត់សំគាល់:** *កិច្ចព្រមព្រៀង ការសន្យា រឺ លិខិតុបករណ៍ មិនចាំបាច់ជា កិច្ចព្រមព្រៀងនេះ រឺ ការសន្យា រឺ លិខិតុបករណ៍ ដែលស្ថិតក្រោមកិច្ចព្រមព្រៀងនេះទេ។ វាអាចធ្វើឡើងជាមួយអ្នកដទៃ ក្រៅពីយើងខ្ញុំ។*

(គ) **មិនមានអ្វីដែលអាចនឹងក្លាយជាការរំលោភលើកិច្ចព្រមព្រៀង:** ការផ្តល់ជាការជូនដំណឹង រឺ ការរំវិវត្តនៃពេលវេលា មិនមែនជាមូលដ្ឋាននៃការគេចផុត ពីការរំលោភលើកិច្ចព្រមព្រៀង ដែលបានបញ្ជាក់ក្នុងកថាខណ្ឌ (ខ) នោះទេ។

(ឃ) **គ្មានអាណត្តិព្យាបាលភាព:** លើកលែងតែមានការជូនដំណឹងជាលាយលក្ខណ៍អក្សរមកយើងខ្ញុំ ទាំងលោក-អ្នក រួមទាំងអ្នកផ្តល់កិច្ចធានា ពុំអាចធ្វើជា អាណត្តិគាហក នៃអាណត្តិព្យាបាលភាពណាមួយបានទេ។

(ង) **គ្មានការលាក់បាំងអំពីផលប្រយោជន៍ក្នុងទ្រព្យធានា:** លើកលែងតែមានការជូនដំណឹងជាលាយលក្ខណ៍អក្សរមកយើងខ្ញុំ ក្រៅពីនេះគឺមិនត្រូវអោយមានបុគ្គលណាមួយ មានផលប្រយោជន៍ក្នុងទ្រព្យធានាចំពោះៈ

(១) ទ្រព្យរបស់លោក-អ្នក រឺ

(២) ទ្រព្យរបស់អ្នកផ្តល់កិច្ចធានាណាម្នាក់ដែលកិច្ចធានានោះ ត្រូវបានផ្តល់ រឺ នឹងផ្តល់ជាកិច្ចធានាមកយើងខ្ញុំ។

(ច) គ្មានការលាក់កំបាំងសំនុំរឿងពាក់ព័ន្ធតុលាការ: លើកលែងតែមានការជូនដំណឹងជាលាយលក្ខណ៍អក្សរមកយើងខ្ញុំ ក្រៅពីនេះ គឺគ្មានបណ្តឹងមជ្ឈត្តកម្ម រឺនីតិវិធីរដ្ឋបាលណាមួយបានកើតឡើង រឺ កំពុងដំណើរការទេ ហើយលោក-អ្នកពុំបានដឹងសោះពីរឿងទាំងនេះដែលអាចគំរាមកំហែង និងអាចមានឥទ្ធិពលអវិជ្ជមានជាសារវ័ន្តទៅលើៈ

(១) អាជីវកម្ម ទ្រព្យសកម្ម រឺ ស្ថានភាពហិរញ្ញវត្ថុរបស់លោក-អ្នក រឺ អ្នកផ្តល់កិច្ចធានា រឺ

(២) លទ្ធភាពរបស់លោក-អ្នក រឺ របស់អ្នកផ្តល់កិច្ចធានា ក្នុងការបំពេញនូវកាតព្វកិច្ចក្រោមឯកសារប្រតិបត្តិការណាមួយ។

(ឆ) **របាយការណ៍ហិរញ្ញវត្ថុរបស់លោក-អ្នក:** របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលថ្មីបំផុតរបស់លោក-អ្នកត្រូវៈ

(១) បង្ហាញនូវភាពពិតប្រាកដ និងត្រឹមត្រូវ ស្តីពីស្ថានភាពហិរញ្ញវត្ថុ និងពីលទ្ធផលនៃប្រតិបត្តិការរបស់លោក-អ្នក សំរាប់ឆ្នាំប្រតិបត្តិការហិរញ្ញវត្ថុនោះ

(២) លាតត្រដាងនូវទ្រព្យអកម្មសំខាន់ៗទាំងអស់ និង

(៣) ប្រសិនបើលោក-អ្នកជាក្រុមហ៊ុនមូលធន នោះត្រូវតែអនុវត្តអោយបានស្របតាមច្បាប់នៃកន្លែងចុះបញ្ជីក្រុមហ៊ុនរបស់លោក-អ្នក និង (លើកលែងតែមានភាពផ្ទុយគ្នាជាមួយច្បាប់ទាំងនោះ) ស្របតាមគោលការណ៍គណនេយ្យដែលបានទទួលស្គាល់ជាទូទៅ នៃកន្លែងចុះបញ្ជីនោះ។

លោក-អ្នកក៏អះអាងផងដែរថា ពុំមានការផ្លាស់ប្តូរអវិជ្ជមានជាសារវ័ន្តណាមួយទៅលើលក្ខខណ្ឌហិរញ្ញវត្ថុរបស់លោក-អ្នក គិតចាប់ពីកាលបរិច្ឆេទចេញរបាយការណ៍ហិរញ្ញវត្ថុនោះ។

(ជ) របាយការណ៍ហិរញ្ញវត្ថុរបស់អ្នកផ្តល់កិច្ចធានាៈ

សំរាប់អ្នកផ្តល់កិច្ចធានាដែលជាក្រុមហ៊ុននីមួយៗ ដែលពាក់ព័ន្ធនឹងលោក-អ្នក របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលថ្មីបំផុតរបស់ក្រុមហ៊ុនត្រូវៈ

(១) បង្ហាញពីភាពពិតប្រាកដ និងត្រឹមត្រូវស្តីពីស្ថានភាពហិរញ្ញវត្ថុ និងពីលទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនសំរាប់ឆ្នាំប្រតិបត្តិការហិរញ្ញវត្ថុនោះ។

(២) លាតត្រដាងនូវទ្រព្យអកម្មសំខាន់ៗទាំងអស់ និង

(៣) អនុវត្តអោយបានស្របតាមច្បាប់នៃកន្លែងចុះបញ្ជីក្រុមហ៊ុន និង (លើកលែងតែមានភាពផ្ទុយគ្នាជាមួយច្បាប់ទាំងនោះ) ស្របតាម គោលការណ៍គណនេយ្យដែលបានទទួលស្គាល់ជាទូទៅ នៃកន្លែងចុះបញ្ជីនោះ។

លោក-អ្នកក៏អះអាងផងដែរថា ពុំមានការផ្លាស់ប្តូរអវិជ្ជមានជាសារវ័ន្តណាមួយទៅលើលក្ខខណ្ឌហិរញ្ញវត្ថុរបស់អ្នកផ្តល់កិច្ចធានា គិតចាប់ពីកាលបរិច្ឆេទចេញរបាយការណ៍ហិរញ្ញវត្ថុនោះ។

(ឈ) **ការលាតត្រដាងទាំងអស់:** លោក-អ្នកត្រូវលាតត្រដាងព័ត៌មានសំខាន់ៗទាំងអស់ ដែលលោក-អ្នកបានដឹងថា អាចផលប៉ះពាល់ដល់៖

(១) អាជីវកម្ម ទ្រព្យសកម្ម រឺ ស្ថានភាពហិរញ្ញវត្ថុរបស់លោក-អ្នក រឺ អ្នកផ្តល់កិច្ចធានា រឺ

(២) លទ្ធភាពរបស់លោក-អ្នក រឺ អ្នកផ្តល់កិច្ចធានា ក្នុងការបំពេញកាតព្វកិច្ចក្រោមឯកសារប្រតិបត្តិការណាមួយ។

(ញ) ការចុះកិច្ចព្រមព្រៀង ការចុះហត្ថលេខាលើឯកសារប្រតិបត្តិការដទៃទៀត និងការអនុវត្តនូវកាតព្វកិច្ចរបស់លោក- អ្នកក្រោមឯកសារទាំងនេះ នឹងមិនផ្ទុយនឹង៖

(១) ច្បាប់ បទបញ្ញត្តិ រឺ តំរូវការ របស់រដ្ឋាភិបាល ដែលអនុវត្តចំពោះលោក-អ្នក រឺ ទ្រព្យណាមួយរបស់លោក-អ្នក

(២) ការអនុញ្ញាត អាជ្ញាប័ណ្ណ រឺ ការលើកលែង ដែលត្រូវអនុវត្តចំពោះលោក-អ្នក រឺ ទ្រព្យណាមួយរបស់លោក-អ្នក

(៣) កិច្ចព្រមព្រៀងដែលភ្ជាប់កាតព្វកិច្ចចំពោះ លោក-អ្នក រឺ ទ្រព្យណាមួយរបស់ លោក-អ្នក

(៤) ឯកសារបង្កើតក្រុមហ៊ុនរបស់លោក-អ្នក ប្រសិនបើលោក-អ្នកជាក្រុមហ៊ុន

(៥) កិច្ចសន្យាបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិ រឺ ឯកសារបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិនេះ ដទៃទៀត ប្រសិនបើលោក-អ្នកជាដៃគូពាណិជ្ជកម្មនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិ

(៦) ឯកសារបញ្ជាក់អាណត្តិព្យាបាលភាព រឺ ឯកសារបង្កើតអាណត្តិព្យាបាលភាពនោះ ប្រសិនបើលោក-អ្នកបានចូលជាគូភាគីនៅក្នុងឯកសារប្រតិបត្តិការណាមួយ ក្នុងនាមជាអាណត្តិគាហកដែលមានអាណត្តិព្យាបាលភាព ។

លោក-អ្នកក៏ធ្វើការធានាអះអាងផងដែរថា ការចុះហត្ថលេខារបស់លោក-អ្នកលើឯកសារទាំងនេះ នឹងមិនចាំបាច់តំរូវអោយមានជាការផ្តល់សិទ្ធិអំណាច អាជ្ញាប័ណ្ណ រឺ ការលើកលែង ដែលលោក-អ្នក ពុំទាន់មាននៅឡើយនោះទេ។

**(ដ) ច្បាប់បរិស្ថាន:** ក្នុងករណីជាសំណុំឥណទានអាជីវកម្ម និងសំណុំឥណទានសាជីវកម្មទូទៅ៖

(១) លោក-អ្នក និងរាល់អ្នកផ្តល់កិច្ចធានាម្នាក់ៗ បានអនុលោមតាមច្បាប់បរិស្ថានទាំងអស់ ដែលពាក់ព័ន្ធនឹងអាជីវកម្ម និងទ្រព្យរបស់លោក-អ្នក និងរាល់អ្នកផ្តល់កិច្ចធានាម្នាក់ៗ និង

(២) លោក-អ្នក និងរាល់អ្នកផ្តល់កិច្ចធានាម្នាក់ៗ បានអនុលោមតាមច្បាប់បរិស្ថានទាំងអស់សំរាប់ទ្រព្យ ដែលបានធានា ឬ ដែលនឹងដាក់ធានា ដោយលោក-អ្នក រឺ អ្នកផ្តល់កិច្ចធានា។

(ឋ) **ភាពមិនផ្ទុយនឹងច្បាប់នៃអ្នកផ្តល់កិច្ចធានា៖**

ការចុះហត្ថលេខាលើឯកសារប្រតិបត្តិការដោយអ្នកផ្តល់កិច្ចធានានៃឯកសារប្រតិបត្តិការណាមួយ និង ការអនុវត្តកាតព្វកិច្ចក្រោមឯកសារទាំងនោះនឹងមិនផ្ទុយនឹង៖

(១) ច្បាប់ រឺ តំរូវការ របស់រដ្ឋាភិបាលដែលអនុវត្តចំពោះអ្នកផ្តល់កិច្ចធានា រឺ ទ្រព្យណាមួយរបស់អ្នកផ្តល់កិច្ចធានា

(២) ការអនុញ្ញាត អាជ្ញាប័ណ្ណ រឺ ការលើកលែង ដែលអនុវត្តចំពោះ អ្នកផ្តល់កិច្ចធានា រឺ ទ្រព្យណាមួយ របស់អ្នកផ្តល់កិច្ចធានា

(៣) កិច្ចព្រមព្រៀងដែលភ្ជាប់កាតព្វកិច្ចលើអ្នកផ្តល់កិច្ចធានា រឺ រាល់សិទ្ធិលើទ្រព្យណាមួយរបស់អ្នកផ្តល់កិច្ចធានា

(៤) ឯកសារបង្កើតក្រុមហ៊ុនរបស់លោក-អ្នក ប្រសិនបើជាក្រុមហ៊ុន

(៥) កិច្ចសន្យាបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិ រឺ ឯកសារបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិដទៃផ្សេងៗទៀត ប្រសិនបើជាសហកម្មសិទ្ធិករ

(៦) ឯកសារបញ្ជាក់អាណត្តិព្យាបាលភាព រឺ ឯកសារបង្កើតអាណត្តិព្យាបាលភាពដទៃទៀត ក្នុងនាមជា អាណត្តិគាហកដែលមាន អាណត្តិព្យាបាលភាព។

លោក-អ្នកក៏ធ្វើការធានាអះអាងផងដែរថា ការចុះហត្ថលេខារបស់លោក-អ្នកលើឯកសារទាំងនេះ នឹងមិនចាំបាច់តំរូវអោយមានជាការផ្តល់សិទ្ធិអំណាច អាជ្ញាប័ណ្ណ រឺ ការលើកលែង ដែលលោក-អ្នកពុំទាន់មាននៅឡើយនោះទេ។

**(២)** រៀងរាល់ពេលដែលលោក-អ្នកធ្វើការដក រឺក៏ប្រើប្រាស់សំណុំឥណទាន លោក-អ្នកនឹងត្រូវធានាអះអាងថា ចំនុចនីមួយៗនៅក្នុងសេចក្តីអះអាង ដែលមានចែងក្នុង ប្រការ ៥(១) គឺត្រឹមត្រូវពិតប្រាកដ។

**(៣)** ក្រោយពីបានធានា រឺ អះអាងអោយដល់យើងខ្ញុំ លោក-អ្នកយល់ព្រមផ្តល់ការជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់មកយើងខ្ញុំ ក្នុងករណីដែលការធានា រឺ ការអះអាង រឺ ព័ត៌មានដែលលោក-អ្នក បានផ្តល់មកយើងខ្ញុំពីមុន លែងជាការពិត រឺ នាំអោយមានការភាន់ច្រឡំនៅពេលនេះ។

## ៦. ការធានារ៉ាប់រង

ប្រសិនបើលិខិតផ្តល់ឥណទានរបស់លោក-អ្នក តំរូវអោយលោក-អ្នកធ្វើការធានារ៉ាប់រងលើទ្រព្យណាមួយៈ

(ក) លោក-អ្នកត្រូវមានធានារ៉ាប់រងលើទ្រព្យនោះ ចំពោះហានិភ័យដែលអាចកើតមានជាធម្មតាទាំងអស់ក្រោមគោលការណ៍ ដែលអាចទទួលយកបានពីយើងខ្ញុំ។ ធនាគារត្រូវតែបានចុះឈ្មោះក្នុងគោលការណ៍ធានារ៉ាប់រង ក្នុងនាមជានិក្ខេបគាហក យ៉ាងត្រឹមត្រូវ។ នៅពេលមុននឹងធ្វើការដកប្រើប្រាស់ សំណុំឥណទាន និង ជាប្រចាំឆ្នាំ លោក-អ្នក ត្រូវផ្តល់អោយយើងខ្ញុំ នូវកំណត់សំអាង ឬ វិញ្ញាបនប័ត្ររូបិយប័ណ្ណ ជាមួយនឹងបង្កាន់ដៃសំរាប់បុព្វលាភ ធានារ៉ាប់រងដែលបានបង់សំរាប់ទ្រព្យ និង

(ខ) យោងទៅតាមវិសាលភាពនៃគោលការណ៍ធានារ៉ាប់រងដែលលោក-អ្នកមានជាធរមានចំពោះទ្រព្យនោះ លោក-អ្នក ត្រូវផ្តល់ភស្តុតាងអោយបានគ្រប់គ្រាន់តាមតំរូវការរបស់យើងខ្ញុំ ដោយបញ្ជាក់ថា បុព្វលាភធានារ៉ាប់រង ដែលបានបង់មកដល់ពេលបច្ចុប្បន្ន គឺគោរពតាមគោលរណ៍ធានារ៉ាប់រង ដែលមានជាធរមាន លើទ្រព្យធានា (ដែលធនាគារបញ្ជាក់ថាត្រឹមត្រូវគ្រប់គ្រាន់តាមលក្ខខណ្ឌ)។

## ៧. ព័ត៌មាន

(ក) លោក-អ្នកយល់ព្រមផ្តល់អោយយើងខ្ញុំនូវព័ត៌មានហិរញ្ញវត្ថុ រឺ ព័ត៌មានដទៃផ្សេងទៀតដែលយើងខ្ញុំបានស្នើសុំ តាមកាលកំណត់។ យើងខ្ញុំយល់ព្រម ស្នើសុំតែព័ត៌មានដែលយើងខ្ញុំយល់ថាមានការពាក់ព័ន្ធប៉ុណ្ណោះ ។ លោក-អ្នកគ្រាន់តែផ្តល់ព័ត៌មានមកយើងខ្ញុំជាលាយលក្ខណ៍អក្សរប៉ុណ្ណោះ ប្រសិនបើយើងខ្ញុំស្នើអោយព័ត៌មាននោះត្រូវផ្តល់ជាលាយលក្ខណ៍អក្សរ។

(ខ) ប្រសិនបើលោក-អ្នក រឺ អ្នកផ្តល់កិច្ចធានា ជាក្រុមហ៊ុនមហាជន លោក-អ្នកក៏យល់ព្រមផ្តល់ជូនយើងខ្ញុំនូវព័ត៌មានជាលាយលក្ខណ៍អក្សរទាំងអស់ដែល លោក-អ្នកបានផ្តល់ទៅឱ្យម្ចាស់ភាគហ៊ុនលោក-អ្នក (ដែលការផ្តល់នោះមានលក្ខណៈជាទូទៅ រឺ ទៅតាមថ្នាក់ណាមួយនៃម្ចាស់ភាគហ៊ុននោះ) រឺ ទៅឱ្យផ្សារហ៊ុននាពេលតំណាលគ្នា ជាមួយនឹងពេលដែលលោក-អ្នកប្រគល់ព័ត៌មាននោះ ដល់ពួកគេទាំងនោះ។

## ៨. ច្បាប់បរិស្ថាន

ក្នុងករណីសំណុំឥណទានអាជីវកម្ម និងសំណុំឥណទានសាជីវកម្មទូទៅ លោក-អ្នកព្រមព្រៀងថាៈ

(ក) គោរពតាម និងធានាថា អ្នកផ្តល់កិច្ចធានានីមួយៗ គោរពតាមលក្ខខណ្ឌតំរូវ តាមបទបញ្ញត្តិច្បាប់បរិស្ថានទាំងអស់ និង

(ខ) ធានាថាអ្នកផ្តល់កិច្ចធានានីមួយៗគោរពតាមលក្ខខណ្ឌតំរូវនៃបទបញ្ញត្តិច្បាប់បរិស្ថានទាំងអស់ ដែលពាក់ព័ន្ធនឹងទ្រព្យដែលបានផ្តល់ ឬ ដែលនឹងផ្តល់ជូនដោយអ្នកផ្តល់កិច្ចធានាមកដល់យើងខ្ញុំ។

## ៩. អត្រាការប្រាក់ប្រែប្រួល

(ក) ប្រសិនបើលិខិតផ្តល់ឥណទានរបស់លោក-អ្នកបានចែងថា អត្រាការប្រាក់នៃសំណុំឥណទានគឺប្រែប្រួល នោះអត្រាការប្រាក់អាចនឹងត្រូវបានធ្វើការកែប្រែដោយធនាគារ ពីពេលមួយទៅពេលមួយ។

(ខ) បំរែបំរួលនៃអត្រាការប្រាក់ដែលអនុវត្តចំពោះសំណុំឥណទានណាមួយ នឹងត្រូវជូនដំណឹងដល់លោក-អ្នក តាមរយៈមធ្យោបាយដូចជា ការផ្សព្វផ្សាយពាណិជ្ជកម្មតាមកាសែតក្នុងស្រុក ឬ តាមការជូនដំណឹងដែលមានបង្ហាញនៅតាមសាខាទាំងឡាយរបស់ធនាគារ។

## ១០. ការវាយតំលៃ

ប្រសិនបើលិខិតផ្តល់ឥណទានរបស់លោក-អ្នកចែងថា ទ្រព្យដែលបានផ្តល់ដល់យើងខ្ញុំជាទ្រព្យធានានឹងតម្រូវអោយមានការវាយតំលៃសារជាថ្មី ឬ ត្រូវតែវាយតំលៃសារជាថ្មីមួយរយៈកាលម្តងៗ នោះៈ

(ក) ការវាយតំលៃសារជាថ្មីណាមួយៈ

(១) ត្រូវតែជាបន្ទុកចំណាយរបស់លោក-អ្នក នៅពេលដែលសំណុំឥណទានបាននឹងកំពុងបន្តផ្តល់ជូនដោយធនាគារ និង

(២) ត្រូវតែធ្វើឡើងដោយភ្នាក់ងារវាយតំលៃអចលនទ្រព្យដែលមានកេរ្តិ៍ឈ្មោះ និង ទទួលយកបានដោយធនាគារហើយ

(ខ) រាល់សំណើដែលមានក្នុងលិខិតផ្តល់ឥណទាននេះ គឺអាស្រ័យទៅតាមលទ្ធផលវាយតំលៃទ្រព្យធានា ដែលធនាគារអាចទទួលយកបាន ។

## ១១. ថ្លៃចំណាយដែលលោក~អ្នកត្រូវបង់

(១) លោក-អ្នកយល់ព្រមបង់ជូនយើងខ្ញុំ តាមការទាមទារ នូវទឹកប្រាក់នៃថ្លៃចំណាយទាំងអស់ ដែលពាក់ព័ន្ធនឹងឯកសារប្រតិបត្តិការ រឺ ប្រតិបត្តិការនានាក្រោម កិច្ចព្រមព្រៀងនេះ ដោយរួមបញ្ចូលទាំងថ្លៃចំណាយរបស់យើងខ្ញុំក្នុងការចាត់វិធានការណាមួយ ទាក់ទងនឹងឯកសារប្រតិបត្តិការ។ ជាពិសេសគឺៈ

(ក) ការចរចារ ការរៀបចំ ការបកប្រែ ការពិនិត្យឡើងវិញ ការធ្វើវិសោធនកម្ម ការអនុវត្ត ការចុះបញ្ជី និង ការបញ្ចប់ រឺ ការបញ្ចេញឯកសារប្រតិបត្តិការ

(ខ) ការគិតថ្លៃ កំរៃផ្សេងៗ រឺ ពន្ធនានា របស់រដ្ឋាភិបាល

(គ) ការវាយតំលៃលើអ្វីមួយដែលយើងខ្ញុំទាមទារឱ្យមានការវាយតំលៃ

(ឃ) ការផ្តល់ការយល់ព្រម ឬ

(ង) ការអោយភាគីអនុវត្តកាតព្វកិច្ច រឺ ការការពារសិទ្ធិយើងខ្ញុំតាមឯកសារប្រតិបត្តិការ។

(២) លោក-អ្នកយល់ព្រមសងយើងខ្ញុំវិញនូវថ្លៃចំណាយ និងការចំណាយនានាដែលកើតឡើងដល់យើងខ្ញុំ ពាក់ព័ន្ធទៅនឹងបញ្ហាណាមួយ ដូចមានក្នុងចំនុច(១) ខាងលើ និង ការសាកសួរ ការជូនដំណឹង រឺ បទបញ្ហាណាមួយពីទីភ្នាក់ងាររដ្ឋាភិបាល (ដែលយើងខ្ញុំចាត់ទុកថា យើងខ្ញុំមានកាតព្វកិច្ចត្រូវអនុវត្តតាម) ដែលពាក់ព័ន្ធនឹង៖

(ក) លោក-អ្នក រឺ អ្នកផ្តល់កិច្ចធានា រឺ បុគ្គលិកក្នុងពេលបច្ចុប្បន្ន រឺ កាលពីអតីតកាលណាមួយរបស់លោក-អ្នក រឺ អ្នកផ្តល់កិច្ចធានា

(ខ) ប្រតិបត្តិការ រឺ សកម្មភាពដែលជាកម្មវត្ថុនៃឯកសារប្រតិបត្តិការ រឺ ដែលតាមរយៈប្រតិបត្តិការ រឺ សកម្មភាពនេះ ប្រភេទនៃឥណទាន រឺ ផលប្រយោជន៍ណាមួយត្រូវបានផ្តល់ជូន រឺ នឹងត្រូវបានផ្តល់ជូនក្រោមឯកសារប្រតិបត្តិការ ដោយរួមបញ្ចូលទាំងការសងមកវិញ ចំពោះការចំណាយពេលវេលា និង ចំណាយគ្រប់គ្រងរបស់យើងខ្ញុំ (ដែលនឹងត្រូវគិតថ្លៃតាមអត្រាសមរម្យ) និងការចំណាយផ្នែកច្បាប់ (រួមបញ្ចូលទាំងមេធាវីរបស់យើងខ្ញុំផងដែរ)។ ទោះបីជាកិច្ចព្រមព្រៀង រឺ សំណុំឥណទានណាមួយក្រោមកិច្ចព្រមព្រៀងនេះបានបញ្ចប់ ក៏ខ្លឹមសារក្នុងវាក្យខ័ណ្ឌនេះ នៅបន្តមានសុពលភាព។

## ផលវិបាកនៃការបញ្ចប់កាតព្វកិច្ច

(៣) បើសិនជាកាតព្វកិច្ចរបស់យើងខ្ញុំពាក់ព័ន្ធនឹងសំណុំឥណទានណាមួយ ត្រូវបានបញ្ចប់៖

(ក) មុនកាលបរិច្ឆេទបញ្ចប់ដោយហេតុផលណាមួយ រឺ

(ខ) ដោយសារយើងខ្ញុំបានជូនដំណឹងដល់លោក-អ្នក ដោយយោងតាមប្រការ ១៥(៣) នោះលោក-អ្នក យល់ព្រមបង់ជូនដល់យើងខ្ញុំ នូវទឹកប្រាក់ដែល យើងខ្ញុំបានកំណត់ ដែលចាំបាច់សំរាប់ធ្វើការសងដល់យើងខ្ញុំចំពោះថ្លៃចំណាយទាំងអស់ ដែលអាចកើតមានមកលើយើងខ្ញុំ រឺ ការខាតបង់ដែលយើងខ្ញុំ អាចនឹងទទួលរងដោយផ្ទាល់ រឺ ដោយប្រយោល ដោយសារតែការបញ្ចប់នោះ។

**សូមប្រុងប្រយ័ត្ន:** ប្រសិនបើលោក-អ្នកបង់ទូទាត់ជាមុននូវសំណុំឥណទានណាមួយ ទឹកប្រាក់នៃថ្លៃចំណាយ រឺ ការខាតបង់អាចនឹងមានទំហំធំធេងពិសេសក្នុង ករណីសំណុំឥណទានដែលមានអត្រាការប្រាក់ថេរ រឺ ផលិតផលសេវាកម្មរតនាគារមួយចំនួន (ដូចជាប្រតិបត្តិការលើការប្តូរពីរូបិយប័ណ្ណមួយទៅរូបិយប័ណ្ណ មួយទៀត "swap transaction") ដែលយើងខ្ញុំបានចុះកិច្ចសន្យាជាមួយនឹងតតិយជន។
ប្រសិនបើលោក-អ្នកមានបំណងធ្វើការបង់ទូទាត់ជាមុននូវសំណុំឥណទានមួយផ្នែក រឺក៏ទាំងអស់ លោក-អ្នកគួរតែពិភាក្សាជាមួយយើងខ្ញុំជាមុន ហើយយើងខ្ញុំ នឹងគណនាថ្លៃចំណាយ រឺ ការខាតបង់ដែលលោក-អ្នកត្រូវតែបង់ទូទាត់។ ធ្វើបែបនេះ នឹងជួយអោយលោក-អ្នកសំរេចចិត្តបានថា តើ លោក-អ្នកនៅតែសំរេចចិត្តបន្តចង់ធ្វើការបង់ទូទាត់ជាមុនទៀតដែរឬទេ។

**កំណត់សំគាល់:** *នៅពេលធ្វើការគណនាថ្លៃចំណាយ រឺ ការខូចខាត នៃការធ្វើការបង់ទូទាត់ជាមុន យើងខ្ញុំនឹងផ្តល់ជូននូវប្រាក់វិភាជន៍ដល់ លោកអ្នកសំរាប់ផលប្រយោជន៍ណាមួយដែលយើងខ្ញុំនឹងទទួលបាន ដោយសារតែការបង់ទូទាត់ជាមុននោះ។*

**ឯកសារកិច្ចធានានានា – ចំណាយ និងកំរៃនានា**

(៤) ប្រសិនបើលិខិតផ្តល់ឥណទានរបស់លោក-អ្នកមានបញ្ចូលនូវតារាងនៃកិច្ចធានានោះ លុះត្រាណាតែយើងខ្ញុំបានចែងនៅក្នុងលិខិតផ្តល់ឥណទានរបស់លោក-អ្នក ពីការទទួលខុសត្រូវលើថ្លៃចំណាយដែលអាចមានចំពោះការរៀបចំ និងការចុះបញ្ជីឯកសារកិច្ចធានា រួមទាំងការទូទាត់ចំពោះការគិតថ្លៃកំរៃផ្សេងៗ រឺ ពន្ធណាមួយពីខាងរដ្ឋាភិបាល បើពុំដូច្នេះទេ លោក-អ្នកយល់ព្រមថាថ្លៃចំណាយទាំងនោះនឹងជាបន្ទុករបស់លោក-អ្នក។

## ១២. ចំនួនទឹកប្រាក់ដែលប្រើហួសកំរិត និង ទឹកប្រាក់ដែលមិនបានបង់តាមកាលកំណត់

(១) លោក-អ្នកយល់ព្រមបង់ទូទាត់ដល់យើងខ្ញុំនូវការប្រាក់ ចំពោះចំនួនទឹកប្រាក់នីមួយៗ (រួមទាំងការប្រាក់) ដែល៖

(ក) ប្រើលើសពីកំរិតកំណត់នៃសំណុំឥណទាន ("ទឹកប្រាក់ប្រើហួសកំរិត")

(ខ) មិនបានបង់នៅពេលដល់កំណត់ ("ទឹកប្រាក់មិនបានបង់តាមកាលកំណត់") ។

(២) អត្រាការប្រាក់សំរាប់ចំនួនទឹកប្រាក់ដែលប្រើហួសកំរិត និង ទឹកប្រាក់ដែលមិនបានបង់តាមកាលកំណត់ គឺជាអត្រាដែលកំណត់ដោយយើងខ្ញុំ ដែលអាចនឹងប្រែប្រួលពីពេលមួយទៅពេលមួយ។ ព័ត៌មានលំអិតនៃអត្រាការប្រាក់នេះគឺមាននៅក្នុងលិខិតផ្តល់ឥណទានរបស់លោក-អ្នក។

(៣) ការប្រាក់បង្គរជារៀងរាល់ថ្ងៃ រាប់បញ្ចូលទាំងថ្ងៃដែល៖

(ក) ទឹកប្រាក់ប្រើហួសកំរិតដំបូងគេដែលបានកើតឡើង ក្នុងករណីជាទឹកប្រាក់ប្រើហួសកំរិត លុះត្រាតែលែងមានទឹកប្រាក់ប្រើហួសកំរិតទៀត រឺ

(ខ) ទឹកប្រាក់ដែលត្រូវដល់ថ្ងៃកំណត់សង ក្នុងករណីជាទឹកប្រាក់ដែលមិនបានបង់តាមកាលកំណត់ លុះត្រាតែទឹកប្រាក់នោះត្រូវបានបង់ទូទាត់រួចហើយ។ លោក-អ្នកយល់ព្រមបង់ទូទាត់ដល់យើងខ្ញុំនូវការប្រាក់នោះ នៅថ្ងៃធ្វើការដំបូងរៀងរាល់ខែនីមួយៗ។

**កំណត់សំគាល់:** *យើងខ្ញុំអាចធ្វើការផ្លាស់ប្តូរថ្ងៃសំរាប់ការបង់ទូទាត់ការប្រាក់នេះ។ សូមមើលប្រការ ១៦។*

(៤) លោក-អ្នកយល់ព្រមបង់ទូទាត់សងមកយើងខ្ញុំតាមការទាមទារ នូវចំនួនទឹកប្រាក់ដែលប្រើហួសកំរិត និងចំនួនទឹកប្រាក់ដែលមិនបានបង់តាមកាលកំណត់ណាមួយនោះ។

(៥) លោក-អ្នកយល់ព្រមបង់ទូទាត់សងដល់យើងខ្ញុំតាមការទាមទារ បន្ថែមពីលើការប្រាក់ដែលត្រូវបង់ យោងតាមអនុប្រការ (១) នូវកំរៃដែលកំណត់ដោយ យើងខ្ញុំ ដែលការប្រាក់និងកំរៃនោះ នឹងធ្វើការទូទាត់ដល់យើងខ្ញុំ ចំពោះថ្លៃចំណាយ រឺ ការខាតបង់ដែលបណ្តាលមកពីចំនួនទឹកប្រាក់ដែលប្រើហួសកំរិត និង ទឹកប្រាក់ដែលមិនបានបង់តាមកាលកំណត់។

(៦) ប្រសិនបើលិខិតផ្តល់ឥណទានសំរាប់សំណុំឥណទានណាមួយរបស់លោក-អ្នក បានបញ្ជាក់អំពីកំរៃទៅលើទឹកប្រាក់ដែលប្រើហួសកំរិតកំរៃនេះ ប្រសិនបើតំរូវអោយបង់ គឺត្រូវបង់នៅថ្ងៃដែលមានទឹកប្រាក់ប្រើហួសកំរិតកើតឡើង និង ទឹកប្រាក់ប្រើហួសកំរិតណាមួយ ដែលអាចកើតមានតាមក្រោយ។

## ការត្រួតពិនិត្យឡើងវិញ

## ១៣. ការត្រួតពិនិត្យឡើងវិញលើសំណុំឥណទាន

*សិទ្ធិ នៃការត្រួតពិនិត្យឡើងវិញ*

(១) យើងខ្ញុំមានសិទ្ធិត្រួតពិនិត្យឡើងវិញចំពោះសំណុំឥណទាន (និងលក្ខខណ្ឌនានានៃសំណុំឥណទាន រួមបញ្ចូលទាំងការកំណត់តំលៃ និងកិច្ចធានា) ស្របទៅតាមប្រការនេះ។

*ចំណុចដែលយើងខ្ញុំអាចធ្វើនៅពេលត្រួតពិនិត្យឡើងវិញ*

(២) តាមរយៈការវាយតំលៃឡើងវិញលើសំណុំឥណទាន ប្រសិនបើយើងខ្ញុំយល់ថាអាចមានការផ្លាស់ប្តូរនៅក្នុងឥណទាន នោះយើងខ្ញុំនឹងផ្តល់ជូនដល់លោក-អ្នក នូវការជូនដំណឹងជាលាយលក្ខណ៏អក្សរ ដោយបញ្ជាក់ថាយើងខ្ញុំមានបំណងៈ

(ក) ធ្វើការកែប្រែលក្ខខណ្ឌណាមួយនៃសំណុំឥណទានដែលបានផ្តល់ជូនលោក-អ្នក រឺ

(ខ) បញ្ចប់នូវសំណុំឥណទានតែម្តង ប៉ុន្តែការបញ្ចប់នេះសំរាប់តែក្នុងករណីដែលលិខិតផ្តល់ឥណទានបញ្ជាក់ថាសំណុំឥណទានជាក់លាក់មួយនោះត្រូវបានផ្តល់ យ៉ាងហោចណាស់រហូតដល់ថ្ងៃត្រួតពិនិត្យឡើងវិញ។

យើងខ្ញុំនឹងផ្តល់ជូនលោក-អ្នកនូវការជូនដំណឹងជាលាយលក្ខណ៏អក្សរដែលមានរយៈពេលយ៉ាងហោចណាស់ ៣០ថ្ងៃ លើកលែងតែលោក-អ្នកបានព្រមព្រៀងលើរយៈពេលជូនដំណឹងខ្លីជាងនេះ។ ប្រសិនបើយើងខ្ញុំបានជូនដំណឹងមុនកាលបរិច្ឆេទនៃការត្រួតពិនិត្យឡើងវិញ រយៈពេលជូនដំណឹងនោះមិនអាចផុតកំណត់មុនកាលបរិច្ឆេទត្រួតពិនិត្យឡើងវិញឡើយ។

**កំណត់សំគាល់:** *អនុប្រការ (២) មិនអនុញ្ញាតិឱ្យយើងខ្ញុំអនុវត្តនូវចំណុចណាមួយនៃចំនុច ខាងក្រោមនេះឡើយ លុះត្រាតែលោក-អ្នកយល់ព្រម រឺ លុះត្រាតែលោក-អ្នករំលោភលើកិច្ចព្រមព្រៀងៈ*

(១) កែប្រែនូវរយៈពេលដែលយើងខ្ញុំបានព្រមព្រៀងជាមួយលោក-អ្នក ដើម្បីរៀបចំផ្តល់សំណុំឥណទាន (សូមមើលប្រការ ២ សំរាប់រយៈពេលដែលបានព្រមព្រៀង)

(២) កែប្រែនូវលក្ខខណ្ឌនៃសំណុំឥណទានមុនកាលបរិច្ឆេទត្រួតពិនិត្យឡើងវិញនោះ រឺ

(៣) កែប្រែនូវលក្ខខណ្ឌនៃសំណុំឥណទាន ប្រសិនបើយើងខ្ញុំបានព្រមព្រៀងពីមុនមកជាមួយលោក-អ្នកជាលាយលក្ខណ៏អក្សរថាយើងខ្ញុំនឹងមិនប្តូរលក្ខខណ្ឌនោះទេ (ឧទាហរណ៏ប្រសិនបើយើងខ្ញុំបានព្រមព្រៀងលើ អត្រាការប្រាក់ថេរសំរាប់រយៈពេលជាក់លាក់មួយ យើងខ្ញុំមិនអាចកែប្រែអត្រាការប្រាក់ថេរនោះសំរាប់អំឡុងពេលនោះទេ) ។

(៣) ប្រសិនបើយើងខ្ញុំបានជូនដំណឹងថា យើងខ្ញុំមានបំណងកែប្រែលក្ខខណ្ឌណាមួយនៃសំណុំឥណទានដែលបានផ្តល់ជូនលោក-អ្នក (លើកលែងតែយើងខ្ញុំបានព្រមព្រៀងផ្ទុយពីនេះជាមួយលោក-អ្នក) នោះៈ

(ក) ការកែប្រែ នឹងមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃដែលលោក-អ្នកយល់ព្រមទទួលការកែប្រែនោះ

(ខ) ប្រសិនបើលោក-អ្នកមិនយល់ព្រមទទួលនូវការកែប្រែទាំងនោះ មុនពេលផុតកំណត់នៃការជូនដំណឹង សំនុំឥណទានទាំងអស់ត្រូវបង់តាមការទាមទារពីខាងយើងខ្ញុំ ដោយគិតចាប់ពីពេលផុតកំណត់នៃការជូនដំណឹង។

(៤) ប្រសិនបើយើងខ្ញុំជូនដំណឹងលោក-អ្នកតាម អនុប្រការ (២) ថា យើងខ្ញុំមានបំណងចង់បញ្ចប់សំណុំឥណទាន ការបញ្ចប់នោះនឹង មានប្រសិទ្ធិភាពនៅពេលផុតកំណត់នៃការជូនដំណឹង។ នៅពេលបញ្ចប់ លោក-អ្នកត្រូវបង់ទូទាត់ដល់យើងខ្ញុំជាបន្ទាន់ នូវទឹកប្រាក់ដែលនៅជំពាក់ក្រោមសំណុំឥណទាន (រួមបញ្ចូលទាំងថ្លៃចំណាយ និងការខាតបង់ ដែលបានកំណត់នៅក្រោមប្រការ ១១ (២))។

*សិទ្ធិរបស់យើងខ្ញុំក្រោមប្រការដទៃទៀត*

(៥) ប្រការនេះ មិនប៉ះពាល់ទៅលើៈ

(ក) សិទ្ធិនានាឯទៀតណាមួយដែលយើងខ្ញុំមាន ប្រសិនបើលោក-អ្នកបានរំលោភលើកិច្ចព្រមព្រៀង ឬក៏

(ខ) សិទ្ធិរបស់យើងខ្ញុំនៅពេលណាមួយ ក្នុងការបញ្ចប់ជាបន្ទាន់នូវសំណុំឥណទាន "តាមការទាមទារ" តាមរយៈការទាមទារឱ្យមានការបង់ទូទាត់។

*ទំរង់នៃការត្រួតពិនិត្យឡើងវិញ*

(៦) ប្រសិនបើលិខិតផ្តល់ឥណទានរបស់លោក-អ្នកចែងថា សំណុំឥណទានរបស់លោក-អ្នកជាកម្មវត្ថុនៃការត្រួតពិនិត្យប្រចាំឆ្នាំ ហើយការត្រួតពិនិត្យប្រចាំឆ្នាំនោះ មិនបានធ្វើមុន រឺ តាមកាលបរិច្ឆេទត្រួតពិនិត្យឡើងវិញ នោះយើងខ្ញុំអាចអនុវត្តនូវការត្រួតពិនិត្យប្រចាំឆ្នាំ នៅពេលណាមួយបន្ទាប់ពីកាលបរិច្ឆេទនៃការត្រួតពិនិត្យឡើងវិញ។

(៧) ប្រសិនបើលិខិតផ្តល់ឥណទានរបស់លោក-អ្នកចែងថា សំណុំឥណទានរបស់លោក-អ្នកជាកម្មវត្ថុនៃការត្រួតពិនិត្យមួយរយៈកាលម្តងៗ យើងខ្ញុំនឹងអនុវត្តសិទ្ធិនេះ តាមឆន្ទានុសិទ្ធិរបស់យើងខ្ញុំ នៅពេលណាមួយក្នុងអំឡុងពេលនៃសំណុំឥណទានរបស់លោក-អ្នក។ យើងខ្ញុំនឹងជូនដំណឹងដល់លោក-អ្នកជាមុន ប្រសិនបើ យើងខ្ញុំសំរេចធ្វើដូច្នេះ ។

*កិច្ចព្រមព្រៀងស្តីពី មូលធនធនាគារក្រុងបាស៊ីល រឺ កាតព្វកិច្ច រឺ បទដ្ឋានគតិយុត្តិសំរាប់របាយការណ៍ហិរញ្ញវត្ថុ (New Basel Capital Accord)*

(៨) ដោយពុំគិតដល់សិទ្ធិដទៃផ្សេងទៀតក្នុងប្រការ ១៣ យើងខ្ញុំអាចត្រួតពិនិត្យឡើងវិញលើសំណុំឥណទាន (និងលក្ខខណ្ឌដើម្បីផ្តល់សំណុំឥណទាន) នៅពេលចាប់ផ្តើម រឺ ពេលអនុវត្ត New Basel Capital Accord ដែលយើងខ្ញុំត្រូវអនុលោមតាម (មិនថាក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា រឺ ច្បាប់ដទៃណាផ្សេងទៀត រឺ ការតំរូវជាអន្តរជាតិ)។ យើងខ្ញុំនឹងជូនដំណឹងដល់លោក-អ្នកពីការត្រួតពិនិត្យឡើងវិញជាលាយលក្ខណ៍អក្សរ និងធ្វើការចរចារដោយសុទ្ធចិត្តជាមួយលោក- អ្នក អំពីលក្ខខណ្ឌនានា (រួមទាំងការកំណត់តំលៃ) នៃសំណុំឥណទាន។ ប្រសិនបើពុំអាចឈានដល់កិច្ចព្រមព្រៀងមួយលើខ្លឹមសារ និងលក្ខខណ្ឌសំរាប់បន្តសំនុំឥណទាន ក្នុងរយៈពេល ៣០ថ្ងៃទេ នោះលោក-អ្នកត្រូវទូទាត់មកវិញទាំងស្រុងនូវសំណុំឥណទានក្នុងរយៈពេល ៩០ថ្ងៃ ចាប់ពីពេលទទួលនូវសេចក្តីជូនដំណឹង ជាលាយលក្ខណ៍អក្សរ។

## ការរំលោភ ឬ ល្មើស ឬ បំពាន លើកិច្ចព្រមព្រៀង ឬ កាតព្វកិច្ច

## ១៤. ការរំលោភលើកិច្ចព្រមព្រៀង

*ព្រឹត្តិការណ៍ដែលជាការរំលោភលើកិច្ចព្រមព្រៀងរបស់អតិថិជន*

(១) នឹងចាត់ទុកថាលោក-អ្នករំលោភលើកិច្ចព្រមព្រៀង ប្រសិនបើមានករណីណាមួយដូចតទៅនេះកើតឡើង៖

(ក) **ការខកខានបង់ទូទាត់**: លោក-អ្នកខកខានបង់ទូទាត់អោយបានទាន់ពេលវេលា នូវទឹកប្រាក់ដែលដល់ពេលកំណត់ និងដែលត្រូវបង់សង ដោយយោងតាមឯកសារប្រតិបត្តិការ។

(ខ) **កិច្ចធានាត្រូវដល់ពេលអនុវត្ត**: មានព្រឹត្តិការណ៍ណាមួយដែលបណ្តាលអោយគូភាគីអនុវត្ត រឺ អាចអនុវត្តកាតព្វកិច្ច ចំពោះផលប្រយោជន៍ក្នុងទ្រព្យធានា រឺ កិច្ចធានាដែលលោក-អ្នកបានផ្តល់ជូន។

(គ) **សេចក្តីអះអាងមិនពិត រឺ បំភាន់**: ការធានាអះអាង រឺ សេចក្តីអះអាង និង ព័តិមានដែលផ្តល់ជូនយើងខ្ញុំ (មិនថាបានធ្វើ រឺផ្តល់មកពេលណាក៏ដោយ) នៅក្នុង រឺ ជាប់ពាក់ព័ន្ធទៅនឹងឯកសារប្រតិបត្តិការ មានលក្ខណៈក្លែងក្លាយ រឺ ធ្វើអោយមានការភាន់ច្រលំ (មិនថាដោយការមិនបញ្ចូលចំណុចណាមួយ រឺ ផ្សេងពីនេះក៏ដោយ) នៅពេលដែលលោក-អ្នកធ្វើ រឺផ្តល់មកយើងខ្ញុំ។

(ឃ) **កាតព្វកិច្ចផ្សេងទៀតដែលពុំទាន់បានបំពេញ**: លោក-អ្នកខកខានបង់ទូទាត់មុនពេលបញ្ចប់រយៈពេលអនុគ្រោះ នូវទឹកប្រាក់ដែលដល់ពេលកំណត់ និងត្រូវសង ទៅភាគីផ្សេងមួយទៀតដែលមិនមែនជាយើងខ្ញុំ ពាក់ព័ន្ធនឹងកាតព្វកិច្ចរបស់លោក-អ្នកចំពោះសំនុំឥណទាន រឺ ការរៀបចំផ្នែកហិរញ្ញវត្ថុ ដទៃផ្សេងទៀត ដែលលោក-អ្នកបានទទួល។

(ង) **ការពន្លឿនកាតព្វកិច្ចដទៃផ្សេងទៀត**: គឺជាកាតព្វកិច្ចណាមួយដែលលោក-អ្នកជំពាក់នរណាម្នាក់ ដែលបានដល់ពេលកំណត់ និងត្រូវសង រឺ អាចត្រូវបានប្រកាសថាដល់ពេលកំណត់ និងត្រូវសងមុនកាលកំណត់ដូចដែលបានបញ្ជាក់ តែនឹងមិនចាត់ជាការល្មើសទេ ប្រសិនបើការពន្លឿននេះ លោក-អ្នកជាអ្នកជ្រើសរើស។

(ច) **ឯកសារប្រតិបត្តិការដែលគ្មានប្រសិទ្ធិភាព**: គឺជាការផ្តល់ឯកសារប្រតិបត្តិការ៖

(១) គ្មានប្រសិទ្ធភាព រឺ លែងមានប្រសិទ្ធភាព ស្របទៅតាមខចែងនៃឯកសារនោះ រឺ

(២) មោឃៈ រឺ នឹងទៅជាមោឃៈ រឺ អាចក្លាយជាមោឃៈ រឺ មិនស្របច្បាប់ រឺ គ្មានសុពលភាព រឺ មិនអាចអនុវត្តបាន។

(ឆ) **ការរឹបអូស រឺ ការអនុវត្ត**: ទ្រព្យខ្លះ រឺ ទ្រព្យទាំងអស់របស់លោក-អ្នក ត្រូវបានរឹបអូសដោយ រឺ ក្នុងនាមឥណទាយក រឺ តាមនីតិវិធីច្បាប់។

(ជ) **ការបញ្ឈប់អាជីវកម្ម**: លោក-អ្នកឈប់ រឺ ទទួលការគំរាមកំហែងអោយឈប់ទាំងស្រុង រឺ ផ្នែកសំខាន់ណាមួយនៃអាជីវកម្មរបស់លោក-អ្នក។

(ឈ) **អសាធនីយភាព**៖

(១) លោក-អ្នកព្យួរទុកនូវការទូទាត់បំណុលរបស់លោក-អ្នក

(២) លោក-អ្នកបញ្ជាក់ថា រឺ ត្រូវបានសន្មតដោយច្បាប់ថា ជួបអសាធនីយ រឺ ពុំអាចសងបំណុលបាន រឺ

(៣) លោក-អ្នកចាត់វិធានការក្នុងគោលបំណងធ្វើការសម្រុះសម្រួល រឺ ការរៀបចំចាត់ចែងណាមួយ ជាមួយឥណទាយករបស់លោក-អ្នក រឺ ជាមួយនរណាមួយនៃសមាជិករបស់ លោក-អ្នក ។

(ញ) **សំណុំឥណទានត្រូវបានប្រើប្រាស់ក្នុងគោលបំណងផ្សេង**: គឺតាមការវិនិច្ឆ័យរបស់យើងខ្ញុំ លោក-អ្នកបានប្រើឥណទានដែលបានផ្តល់ក្រោមសំណុំឥណទាន សំរាប់គោលបំណងមួយផ្សេងក្រៅពីគោលបំណងដែលយើងខ្ញុំយល់ព្រមផ្តល់ឥណទានជូន។

(ដ) **ការផ្លាស់ប្តូរនៃកាលៈទេសៈ**: គឺកាលៈទេសៈនានាដែលបានកើតឡើងដែលតាម ការវិនិច្ឆ័យរបស់យើងខ្ញុំ កាលៈទេសៈនោះអាចបង្កអោយមានឥទ្ធិពល អវិជ្ជមានជាសារវ័ន្តទៅលើ៖

(១) អាជីវកម្ម ទ្រព្យសកម្ម រឺ ស្ថានភាពហិរញ្ញវត្ថុ របស់លោក-អ្នក រឺ

(២) លទ្ធភាពរបស់លោក-អ្នកក្នុងការបំពេញកាតព្វកិច្ចរបស់លោក-អ្នក ក្រោមឯកសារប្រតិបត្តិការណាមួយ។

(ឋ) **ព្រឹត្តិការណ៍ដទៃផ្សេងទៀតដែលមានបញ្ជាក់ក្នុងលិខិតផ្តល់ឥណទាន**: គឺព្រឹត្តិការណ៍មួយកើតឡើងដែលមានបញ្ជាក់ក្នុង លិខិតផ្តល់ឥណទានថាជាព្រឹត្តិការណ៍នៃការរំលោភលើកិច្ចព្រមព្រៀង។

(ឌ) **ការជូនដំណឹងរបស់គតិយជនរក្សាទ្រព្យ**: ការជូនដំណឹងរបស់គតិយជនរក្សាទ្រព្យ (រឺ ការជូនដំណឹងណាមួយក៏ដោយ (ទោះហៅរបៀបណាក៏ដោយ) ដែលតាមរយៈនោះ យើងខ្ញុំត្រូវបានតំរូវអោយធ្វើការទូទាត់ប្រាក់ ស្របតាមសេចក្តីជូនដំណឹងនោះ ដោយពុំគិតពីការណែនាំផ្ទុយណាមួយដែលលោកអ្នកអាចនឹងផ្តល់ជូនដល់យើងខ្ញុំ) ធ្វើឡើងពាក់ព័ន្ធទៅនឹងពន្ធ រឺ ប្រាក់ដទៃទៀត ដែលតាមការជូនដំណឹងបែបនេះបង្ហាញថាលោក-អ្នកជាអ្នកជំពាក់។

(ណ) **ការខកខានក្នុងការអនុវត្តកាតព្វកិច្ច**: គឺលោក-អ្នកបំពានលើកាតព្វកិច្ចដែលមានក្រោមឯកសារប្រតិបត្តិការ និងចំនុចណាមួយ ដូចខាងក្រោមនេះ៖

(១) ការបំពាននេះមិនអាចដោះស្រាយបាន រឺ

(២) ប្រសិនបើការបំពាននេះអាចដោះស្រាយបាន យើងខ្ញុំផ្តល់ជូនលោក-អ្នកនូវសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរដែលតំរូវឱ្យលោក-អ្នកដោះស្រាយការបំពាននោះ ក៏ប៉ុន្តែ រយៈពេល៥ថ្ងៃក្រោយមក នៅតែមិនអាចដោះស្រាយបាន។

*ក្រុមហ៊ុនមូលធន - ព្រឹត្តិការណ៍បន្ថែមដែលជាការរំលោភលើកិច្ចព្រមព្រៀង*

**(២)** ប្រសិនបើលោក-អ្នកជាក្រុមហ៊ុនមូលធន លោក-អ្នកក៏នឹងត្រូវចាត់ទុកថារំលោភលើកិច្ចព្រមព្រៀងផងដែរ ប្រសិនបើចំនុចណាមួយដូចតទៅនេះកើតឡើង៖

(ក) **ការរំលាយ និងការជំរះបញ្ជី**: គឺជាពាក្យស្នើសុំដែល ត្វវបានធ្វើឡើង ដំណោះស្រាយមួយដែលត្រូវបានអនុម័ត រឺ បទបញ្ជាមួយដែលត្រូវបានធ្វើឡើងអោយមានការរំលាយ រឺ ការជំរះបញ្ជីក្រុមហ៊ុនរបស់លោក-អ្នក។

(ខ) **ការគ្រប់គ្រងជំនួស។ល។** ហិតូបត្ថម្ភកៈ អ្នកគ្រប់គ្រងទ្រព្យបណ្តោះអាសន្ន អ្នកចាត់ការអ្នកគ្រប់គ្រងទ្រព្យបណ្តោះអាសន្ន (receiver-manager) រឺ បុគ្គលិក ប្រហែលត្រូវបានជ្រើសតាំងដល់លោកអ្នក រឺផ្នែកណាមួយនៃទ្រព្យរបស់លោកអ្នក រឺមាននរណាម្នាក់បានចាត់វិធានការក្នុងគោលបំណងនេះ។

(គ) **ការរក្សាដើមទុន**: គឺ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីយើងខ្ញុំ លោក-អ្នកបានអនុម័តសេចក្តីសំរេច រឺ ចាត់វិធានការ ដើម្បី៖

(១) កាត់បន្ថយភាគទុនរបស់លោក-អ្នក

(២) ដាក់កំរិតលទ្ធភាពរបស់លោក-អ្នកក្នុងការទាមទារមកវិញនូវដើមទុនបំរុង

(៣) ទិញភាគហ៊ុនខ្លួនឯង ជាជាងទិញត្រឡប់មកវិញនូវភាគហ៊ុនអាទិភាពដែលអាចទិញត្រឡប់មកវិញបាន។

*រូបវ័ន្តបុគ្គល - ព្រឹត្តិការណ៍បន្ថែមនៃការរំលោភលើកិច្ចព្រមព្រៀង*

**(៣)** ប្រសិនបើលោក-អ្នកជា រូបវ័ន្តបុគ្គល (រួមទាំងដៃគូរផង) លោក-អ្នកក៏រំលោភលើកិច្ចព្រមព្រៀងដែរ ប្រសិនបើចំនុចណាមួយនៃចំនុចដូចតទៅនេះកើតឡើង៖

(ក) **សកម្មភាពអសាធនភាព**: គឺ លោក-អ្នកប្រព្រឹត្តនូវសកម្មភាពដែលជាអសាធនភាព

(ខ) **ការជូនដំណឹងពីអសាធនភាព**: គឺ ការជូនដំណឹងស្តីពី អសាធនភាព ក្ស័យធន រឺ ការជូនដំណឹងប្រហាក់ប្រហែលគ្នា ត្រូវបានចេញចំពោះលោក-អ្នក។

(គ) **មានអសាធនភាព**: លោក-អ្នកបានក្លាយជាអសាធន (ទោះបីពាក្យអសាធនភាព ត្រូវបានបកស្រាយក្នុងច្បាប់ដែលយកមកអនុវត្តណាក៏ដោយ) រឺ

(ឃ) **ហិតូបត្ថម្ភកៈត្រូវបានតែងតាំង**: អ្នកគ្រប់គ្រង រឺ អាណត្តិគាហកដទៃទៀតសំរាប់គណទាយក ត្រូវបានតែងតាំងឡើងពាក់ព័ន្ធ នឹងទ្រព្យណាមួយនៃទ្រព្យរបស់លោក-អ្នក ក្នុងពេលអសាធននោះ។

*ក្រុមហ៊ុនសហកម្មសិទ្ធិ - ព្រឹត្តិការណ៍បន្ថែមនៃការរំលោភលើកិច្ចព្រមព្រៀង*

**(៤)** ប្រសិនបើលោក-អ្នកជាក្រុមហ៊ុនសហកម្មសិទ្ធិ លោក-អ្នកក៏នឹងត្រូវចាត់ទុកថាបានរំលោភលើកិច្ចព្រមព្រៀងដែរ ប្រសិនបើចំណុចដូចតទៅនេះបានកើតឡើង៖

(ក) **ការកែប្រែនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធ**: គឺដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីយើងខ្ញុំ មានការកែប្រែក្នុងកិច្ចសន្យា ក្រុមហ៊ុនសហកម្មសិទ្ធិ រឺ ឯកសារបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិដទៃទៀត រឺ

(ខ) **ការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិ**: គឺដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីយើងខ្ញុំ ក្រុមហ៊ុនសហកម្មសិទ្ធិត្រូវបានរំលាយ រឺ ធ្វើការជំរះបញ្ជី។

*អ្នកផ្តល់កិច្ចធានា*

**(៥)** អនុប្រការ (១) ដល់ (៤) (អាចត្រូវកែប្រែតាមការចាំបាច់) ត្រូវអនុវត្តចំពោះអ្នកផ្តល់កិច្ចធានា។ ប្រសិនបើអ្នកផ្តល់កិច្ចធានារំលោភកិច្ចព្រមព្រៀងនោះលោក-អ្នកក៏រំលោភលើកិច្ចព្រមព្រៀងដែរ។

*លោក-អ្នកនឹងជូនដំណឹងយើងខ្ញុំពីការរំលោភលើកិច្ចព្រមព្រៀង*

**(៦)** លោក-អ្នកយល់ព្រមជូនដំណឹងដល់យើងខ្ញុំជាលាយលក្ខណ៍អក្សរជាបន្ទាន់ ប្រសិនបើលោក-អ្នកបានរំលោភលើកិច្ចព្រមព្រៀង រឺក៏ មានព្រឹត្តិការណ៍ដែលអាចជាការរំលោភលើកិច្ចព្រមព្រៀងកើតឡើង។

## ១៥. ផលវិបាកនៃការរំលោភលើកិច្ចព្រមព្រៀង

*សិទ្ធិជ្រើសរើសរបស់យើងខ្ញុំ*

(១) ប្រសិនបើលោក-អ្នករំលោភលើកិច្ចព្រមព្រៀង (តាមការសំរេចរបស់យើងខ្ញុំ) យើងខ្ញុំអាចលះបង់ចោលសិទ្ធិណាមួយ រឺ ទាំងអស់ ដែលយើងខ្ញុំមាន។

**សំគាល់:** *ប្រការ ២១ ចែងអំពីការលះបង់សិទ្ធិ។*

(២) ប្រសិនបើលោក-អ្នករំលោភលើកិច្ចព្រមព្រៀង យើងខ្ញុំអាចអនុវត្តនូវចំណុចណាមួយ រឺ ច្រើនដូចខាងក្រោមៈ

(ក) បញ្ចប់ជាបន្ទាន់នូវកាតព្វកិច្ចខ្លះ រឺ ទាំងអស់របស់ យើងខ្ញុំក្រោមកិច្ចព្រមព្រៀងនេះ។

(ខ) កែប្រែជាបន្ទាន់នូវលក្ខខណ្ឌខ្លះ រឺ ទាំងអស់ទៅលើសំណុំឥណទានមួយ រឺ ច្រើនដែលត្រូវរៀបចំផ្តល់ជូន (ឧទាហរណ៍ យើងខ្ញុំអាចលុបចោលនូវកំរិតឥណទាន ដែលមិនទាន់បានប្រើប្រាស់ ដោយកាត់បន្ថយកំរិតឥណទានចំពោះសំណុំឥណទាននោះ រឺ យើងខ្ញុំអាចធ្វើសំណុំឥណទាននោះឱ្យទៅជា "តាមការទាមទារ")

(គ) ធ្វើអោយប្រាក់ខ្លះ រឺ ប្រាក់ទាំងអស់ដែលបានជំពាក់ រឺ នឹងជំពាក់យើងខ្ញុំ ពាក់ព័ន្ធនឹងសំណុំឥណទានរបស់លោកអ្នក ដល់កំណត់ភ្លាម១ និងត្រូវសងមកយើងខ្ញុំ (ដោយរួមបញ្ចូលទាំងតំលៃលើវិក្កយប័ត្រនានា ដែលមិនទាន់បានទូទាត់ទាំងអស់) និង

(ឃ) តំរូវឱ្យលោក-អ្នកផ្តល់មកអោយយើងខ្ញុំនូវសាច់ប្រាក់គ្រប់គ្រាន់ដើម្បីប៉ះប៉ូវយើងខ្ញុំចំពោះការទទួលខុសត្រូវណាមួយដែលនឹងអាចកើតមានឡើង (ឧទាហរណ៍ ការទទួលខុសត្រូវដែលអាចកើតមានឡើងក្រោមលិខិតឥណទាន) ។

(៣) យើងខ្ញុំនឹងផ្តល់ជូនលោក-អ្នកនូវការជូនដំណឹងជាលាយលក្ខណ៍អក្សរ ក្រោយពីបានអនុវត្តតាម អនុប្រការ (២)(ក) ឬ (ខ)។

(៤) យើងខ្ញុំនឹងផ្តល់ជូនលោក-អ្នកនូវការជូនដំណឹងជាលាយលក្ខណ៍អក្សរ មុនពេលធ្វើការអនុវត្តតាម អនុប្រការ (២)(គ) ឬ (ឃ)។ សេចក្តីជូនដំណឹងនេះមានប្រសិទ្ធិភាពភ្លាម១ នៅពេលយើងខ្ញុំធ្វើការជូនដំណឹង។

*លោក-អ្នកយល់ព្រមទូទាត់សំណងដល់យើងខ្ញុំនូវការខាតបង់ ដែលបណ្តាលមកពីការរំលោភលើកិច្ចព្រមព្រៀង*

(៥) លោក-អ្នកយល់ព្រមបង់ទូទាត់ដល់យើងខ្ញុំតាមការទាមទារ នូវទឹកប្រាក់នៃថ្លៃចំណាយទាំងអស់ដែលកើតឡើងមកលើយើងខ្ញុំ និងការខាតបង់ទាំងឡាយ ដែលយើងខ្ញុំបានទទួលរងដោយសារ រឺក៏ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍នៃការរំលោភលើកិច្ចព្រមព្រៀង។ ដោយមិនគិតថាប្រាក់នេះអាចមានទំហំប៉ុណ្ណា សំណងនេះត្រូវរាប់បញ្ចូលនូវទឹកប្រាក់ណាក៏ដោយដែលយើងខ្ញុំបានកំណត់ថា ចាំបាច់ដើម្បីសងដល់យើងខ្ញុំចំពោះ ថ្លៃចំណាយដែលយើងខ្ញុំបានបង់ រឺ ការខាតបង់ដែលយើងខ្ញុំបានទទួលរង ដោយសារការទូទាត់មុនពេលកំនត់នូវប្រាក់ ដែលនៅជំពាក់។ យើងខ្ញុំនឹងធ្វើការគិតគូរផងដែរនូវផលប្រយោជន៍ណាមួយ ដែលតាមការវិនិច្ឆ័យរបស់យើងខ្ញុំ យើងខ្ញុំនឹងបានទទួលដោយសារតែការបង់ទូទាត់ប្រាក់មុនពេលកំនត់ រឺ ការខកខានទូទាត់ប្រាក់នោះ។

*ការរំលោភលើកិច្ចព្រមព្រៀងជះឥទ្ធិពលលើកិច្ចព្រមព្រៀងដទៃទៀតជាមួយយើងខ្ញុំ*

(៦) លោក-អ្នកយល់ព្រមថាព្រឹត្តិការណ៍នៃការរំលោភលើកិច្ចព្រមព្រៀង ក្រោមកិច្ចព្រមព្រៀងនេះ គឺជាព្រឹត្តិការណ៍នៃការរំលោភលើកិច្ចព្រមព្រៀង រឺ ព្រឹត្តិការណ៍នៃការពន្លឿនកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀងដទៃទៀតទាំងអស់ដែលលោក-អ្នកមានជាមួយយើងខ្ញុំ។ ឧទាហរណ៍: អនុប្រការនេះអនុវត្តចំពោះការរំលោភលើកិច្ចព្រមព្រៀងក្រោមកិច្ចធានាមួយ។ អនុប្រការនេះនឹងអនុវត្ត បើទោះបីមាន អ្វីចែងនៅក្នុង កិច្ចព្រមព្រៀងឯទៀតណាក៏ដោយ។

# ការបង់ទូទាត់

## ១៦. ការបង់ទូទាត់ជាទូទៅ

*ការបង់ទូទាត់ត្រូវតែជំរះបានភ្លាម១*

(១) រាល់ការបង់ទូទាត់ដែលលោក-អ្នកបានធ្វើមកកាន់យើងខ្ញុំ ត្រូវតែជាប្រាក់ដែលអាចទូទាត់បានភ្លាម១។

*កាលបរិច្ឆេទត្រូវធ្វើការបង់ទូទាត់ ដែលមិនមែនជាថ្ងៃធ្វើការ*

(២) លើកលែងតែកិច្ចព្រមព្រៀងចែងផ្សេងពីនេះ ប្រសិនបើថ្ងៃដល់កំណត់សំរាប់ការបង់ទូទាត់មិនមែនជាថ្ងៃធ្វើការ ទឹកប្រាក់នោះត្រូវបង់ នៅថ្ងៃធ្វើការមុនថ្ងៃ ដែលមិនមែនជាថ្ងៃធ្វើការនោះ។ កាលណាថ្ងៃដល់កំណត់នោះចំថ្ងៃទី ២៩ រឺ ៣០ រឺ ៣១ នៃ ខែដែលមិនមានថ្ងៃដូចនោះ ការទូទាត់នោះនឹងត្រូវដល់កំណត់នៅថ្ងៃចុងក្រោយនៃខែនោះ។

*យើងខ្ញុំអាចធ្វើការបង់ទូទាត់ពីគណនីរបស់លោក-អ្នក ដែលមានជាមួយយើងខ្ញុំ*

(៣) លោក-អ្នកផ្តល់សិទ្ធិអោយយើងខ្ញុំចុះឥណពន្ធ (កាត់ប្រាក់ចេញពី) ក្នុងគណនីណាមួយរបស់លោក-អ្នក នូវទឹកប្រាក់ដែលត្រូវបង់ដោយលោក-អ្នកក្រោមកិច្ចព្រមព្រៀងនេះ។ យើងខ្ញុំអាចចុះឥណពន្ធនូវទឹកប្រាក់ណាមួយពីក្នុងគណនីរបស់លោក-អ្នកដោយពុំចាំបាច់ធ្វើការទាមទារបើទោះបីបញ្ញត្តិឯទៀតនៃកិច្ចព្រមព្រៀងនេះចែងថាទឹកប្រាក់នេះត្រូវបង់តាមការទាមទារក៏ដោយ។ ទោះជាយ៉ាងណាក៏ដោយ យើងខ្ញុំមិនចាំបាច់ចុះឥណពន្ធលើគណនីលោក-អ្នក ហើយយើងខ្ញុំអាចស្នើសុំអោយលោក-អ្នក ទូទាត់ទឹកប្រាក់នោះមកយើងខ្ញុំតែម្តង។ ប្រសិនបើយើងខ្ញុំចុះឥណពន្ធក្នុងគណនីរបស់លោក-អ្នក យើងខ្ញុំនឹងជូនដំណឹងដល់លោក-អ្នកជាលាយលក្ខណ៍អក្សរពីការដែលយើងខ្ញុំបានធ្វើដូច្នេះ។

*កំណត់សំគាល់: ឧទាហរណ៍ ប្រការ ១១ (១) នៃកិច្ចព្រមព្រៀងនេះ តំរូវអោយលោក-អ្នកបង់តាមការទាមទារនូវថ្លៃចំណាយជាក់លាក់នានាដែលពាក់ព័ន្ធ(ដូចជាការគិតថ្លៃពីរដ្ឋាភិបាល កំរៃរដ្ឋបាល ពន្ធ និង កំរៃចុះបញ្ជីលើកិច្ចធានា)។ ប្រការ ១៦ (៣) អនុញ្ញាតិអោយយើងខ្ញុំចុះឥណពន្ធចំពោះកំរៃទាំងនេះក្នុង គណនីរបស់លោក-អ្នក ដោយមិនចាំបាច់អោយមានការទាមទារជាផ្លូវការឡើយ។ ទឹកប្រាក់ដទៃទៀត ដែលអាចនឹងត្រូវបានចុះឥណពន្ធក្នុងគណនីរបស់លោក-អ្នក គឺរួមបញ្ចូលទាំងការប្រាក់នៃសំណុំឥណទានដែលត្រូវដល់កំណត់។*

*យើងខ្ញុំអាចកែប្រែពេលវេលាសំរាប់ការបង់ទូទាត់ការប្រាក់*

(៤) នៅពេលណាក៏ដោយ យើងខ្ញុំអាចធ្វើការកែប្រែចំពោះ ពេលវេលា ភាពញឹកញាប់ និង របៀបដែលលោក-អ្នកនឹងបង់ទូទាត់ការប្រាក់មកអោយយើងខ្ញុំ ក្រោមសំណុំឥណទានណាមួយក៏ដោយ។

*កំណត់សំគាល់: ប្រសិនបើយើងខ្ញុំធ្វើការផ្លាស់ប្តូរប្រភេទនេះ យើងខ្ញុំនឹងផ្តល់នូវការជូនដំណឹងអំពីការផ្លាស់ប្តូរនោះ មុនពេលធ្វើការផ្លាស់ប្តូរ។ យើងខ្ញុំនឹងធ្វើដូចនេះដោយជូនដំណឹងលោក-អ្នកជាលាយលក្ខណ៍អក្សរ មិនអោយយឺតជាង៣០ថ្ងៃ មុនពេលដែលការកែប្រែនោះមានប្រសិទ្ធិភាព។*

*ការកែប្រែចំពោះកំរៃ និង ការគិតថ្លៃ*

(៥) យើងខ្ញុំអាចនឹងដាក់អោយអនុវត្តនូវកំរៃ រឺ ការគិតថ្លៃថ្មីសំរាប់សំណុំឥណទាន។ យើងខ្ញុំក៏អាចធ្វើការកែប្រែនូវ កំរៃ រឺ ការគិតថ្លៃដែលកំពុងមាន ក៏ដូចជាពេលវេលា ភាពញឹកញាប់ ព្រមទាំងរបៀប ដែលលោក-អ្នកបង់ទូទាត់ការគិតថ្លៃទាំងនេះ។ កំរៃ រឺ ការគិតថ្លៃ រឺ ការកែប្រែថ្មីណាមួយ នឹងត្រូវបានជូនដំណឹងដល់លោក-អ្នក មិនអោយយឺតជាងថ្ងៃដែលការកែប្រែនោះចាប់មានប្រសិទ្ធិភាពឡើយ។

*ការកែប្រែចំពោះឈ្មោះ*

(៦) យើងខ្ញុំអាចកែប្រែឈ្មោះណាមួយនៃឈ្មោះរបស់អត្រាការប្រាក់ សំណុំឥណទាន រឺ ការបោះពុម្ពផ្សាយណាមួយរបស់យើងខ្ញុំ។

*ការជូនដំណឹង*

(៧) យើងខ្ញុំអាចជូនដំណឹងដល់លោក-អ្នកតាម ប្រការ ១៦ (៥) រឺ ១៦ (៦) តាមរយៈសេចក្តីជូនដំណឹងដែលបានផ្តល់ជូនលោក-អ្នកជាលាយលក្ខណ៍អក្សរ រឺ តាមរយៈសេចក្តីជូនដំណឹង ដែលដាក់តាំងបង្ហាញនៅតាមសាខាណាមួយនៃសាខាទាំងឡាយរបស់យើងខ្ញុំ នៅលើគេហទំព័ររបស់យើងខ្ញុំ រឺ តាមរយៈការផ្សាយពាណិជ្ជកម្មនៅក្នុងសារព័ត៌មានធំៗ ឬ សារព័ត៌មានប្រចាំថ្ងៃរបស់ជាតិ។ លោកអ្នកនឹងត្រូវបានសន្មតថាបានទទួលនូវការជូនដំណឹងនោះភ្លាមៗក្រោយពីមានការដាក់តាំងបង្ហាញ រឺ ការផ្សាយពាណិជ្ជកម្មដូចនោះ។

*យើងខ្ញុំនឹងផ្តល់ជូនលោក-អ្នកនូវព័ត៌មានស្តីពី អត្រាការប្រាក់បច្ចុប្បន្ន កំរៃ និងការគិតថ្លៃជាបទដ្ឋាន*

(៨) ព័ត៌មានស្តីពីអត្រាការប្រាក់បច្ចុប្បន្ន កំរៃ និងការគិតថ្លៃជាបទដ្ឋានរបស់យើងខ្ញុំ នឹងត្រូវរៀបចំផ្តល់ជូនដល់លោក-អ្នកតាម ការស្នើសុំពីប្រធានផ្នែកទំនាក់ទំនងរបស់លោក-អ្នក។

*ការទូទាត់សងចំពោះសំណុំឥណទានដោយមូលប្បទានប័ត្រ*

(៩) ប្រសិនបើលោក-អ្នកអាចធ្វើការទូទាត់សងចំពោះសំណុំឥណទានរបស់លោក-អ្នកតាមរយៈមូលប្បទានប័ត្រ ហើយមូលប្បទានប័ត្រ នោះត្រូវបានទទួលការបដិសេធ ការទូទាត់សងនឹងត្រូវចាត់ទុកជាមិនបានការឡើយ ហើយការប្រាក់នឹងបន្តបង្គរទៅលើសមតុល្យប្រចាំថ្ងៃដែលមិនទាន់បានបង់រហូតទាល់តែការទូទាត់ពិតប្រាកដត្រូវបានទទួលដោយយើងខ្ញុំ។

## ១៧. គ្មានការកាត់បន្ថយពីការបង់ទូទាត់នានារបស់លោក~អ្នក

*ការបង់ទូទាត់នឹងត្រូវបានធ្វើឡើងដោយគ្មានការកាត់បន្ថយ*

(១) លោក-អ្នកយល់ព្រមធ្វើការបង់ទូទាត់នីមួយៗមកដល់យើងខ្ញុំ តាមកិច្ចព្រមព្រៀងនេះ ដោយគ្មានៈ

(ក) ការទូទាត់-កាត់កង (set-off) រឺ ការទាមទារតប (counterclaim)

(ខ) ការកាត់បន្ថយ (deduction) រឺ

(គ) ការកាត់ទុកសំរាប់ រឺ ទៅលើគណនីចំពោះពន្ធ រឺ អាករ (ក្នុងវិសាលភាពអតិបរមាដែលច្បាប់បានអនុញ្ញាតិ)។

*ប្រសិនបើពន្ធកាត់ទុក រឺ ការកាត់បន្ថយដទៃទៀតត្រូវបានធ្វើឡើង*

(២) លោក-អ្នកយល់ព្រមដូច្នេះថា ប្រសិនបើច្បាប់បានតំរូវឱ្យលោក-អ្នកធ្វើការកាត់បន្ថយ រឺ កាត់ទុក រឺ បន្ថយដោយត្រូវអោយបង់លើអាករ រឺ ពន្ធ ចេញពីការបង់ទូទាត់របស់លោក-អ្នកមកយើងខ្ញុំ (ក្រៅពីអ្វីទាំងឡាយដែលបានអនុវត្តទៅលើប្រាក់ចំណូលសុទ្ធទាំងមូលរបស់យើងខ្ញុំ)ៈ

(ក) លោក-អ្នកនឹងបង់មកអោយយើងខ្ញុំនៅពេលដែលការបង់ទូទាត់នោះដល់កំណត់ នូវទឹកប្រាក់បន្ថែមណាមួយក៏ដោយដែលចាំបាច់លៃយ៉ាងណាធ្វើអោយ អ្វីដែលយើងខ្ញុំទទួលបានពិតប្រាកដក្រោយពីការកាត់បន្ថយ រឺ ការកាត់ទុកនោះ គឺជាចំនួនទឹកប្រាក់ពេញលេញដែលយើងខ្ញុំគួរតែមានសិទ្ធិទទួលបាន ទោះបីជាមានការកាត់បន្ថយ រឺ ការកាត់ទុកត្រូវបានធ្វើឡើងក៏ដោយ។

(ខ) លោក-អ្នកនឹងសងត្រលប់មកយើងខ្ញុំវិញចំពោះការខាតបង់ណាមួយ ដែលយើងខ្ញុំទទួលរង រឺ ថ្លៃចំណាយដែលយើងខ្ញុំបានពាក់ព័ន្ធ ដោយសារតែលោកអ្នកមិនបានធ្វើការកាត់បន្ថយ រឺ ដកពន្ធកាត់ទុកនោះ និង

(គ) លោក-អ្នកនឹងផ្តល់ជូនមកយើងខ្ញុំភ្លាមនូវច្បាប់ថតចំលងណាមួយដែលពាក់ព័ន្ធនឹងទឹកប្រាក់ដែលលោក-អ្នកបានបង់ រឺ ត្រូវបង់ ដែលពាក់ព័ន្ធនឹងការកាត់បន្ថយ រឺ ពន្ធកាត់ទុកទាំងនោះ។

## ១៨. រូបិយប័ណ្ណខុសគ្នា

*ដុល្លារសហរដ្ឋអាមេរិក*

(១) លើកលែងតែឯកសារប្រតិបត្តិការបានចែងផ្សេងពីនេះ ការបង់ទូទាត់ទាំងអស់ដែលបានធ្វើឡើងក្រោម រឺ សំរាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ រឺ ឯកសារប្រតិបត្តិការផ្សេងទៀត ត្រូវតែធ្វើឡើងជាដុល្លារសហរដ្ឋអាមេរិក។

*ការប្តូរពីរូបិយប័ណ្ណមួយទៅរូបិយប័ណ្ណមួយទៀត*

(២) វិធីសាស្ត្រដើម្បីអនុវត្តសំរាប់ប្តូរពីរូបិយប័ណ្ណមួយទៅ រូបិយប័ណ្ណមួយទៀត នឹងត្រូវបានធ្វើឡើងតាមបទដ្ឋានរបស់ យើងខ្ញុំសំរាប់ការប្តូររូបិយប័ណ្ណ។

*ប្រសិនបើលោក-អ្នកធ្វើការបង់ទូទាត់ជារូបិយប័ណ្ណផ្សេង*

(៣) អនុប្រការនេះនឹងត្រូវអនុវត្ត ប្រសិនបើមានច្បាប់តំរូវ រឺ សេចក្តីបង្គាប់របស់តុលាការ រឺ សំរាប់ហេតុផលណាមួយ ការបង់ទូទាត់ក្រោមកិច្ចព្រមព្រៀងនេះ រឺ ឯកសារប្រតិបត្តិការផ្សេងទៀត ត្រូវធ្វើឡើងជារូបិយប័ណ្ណមួយផ្សេងពីរូបិយប័ណ្ណដែលបានតំរូវអោយប្រើបង់ទូទាត់ ក្រោមឯកសារប្រតិបត្តិការពាក់ព័ន្ធនោះ។ ប្រសិនបើទឹកប្រាក់នោះត្រូវបានបង់ជារូបិយប័ណ្ណផ្សេង ហើយក្រោយពេលដែលយើងខ្ញុំបានប្តូររូបិយប័ណ្ណ ទឹកប្រាក់នោះមិនគ្រប់តាមចំនួនត្រូវសង និងត្រូវបង់ តាមឯកសារប្រតិបត្តិការដែលពាក់ព័ន្ធ លោក-អ្នកយល់ព្រមបង់ទូទាត់មកអោយយើងខ្ញុំតាមការទាមទារ នូវទឹកប្រាក់ដែលនៅខ្វះនោះ ដោយសារតែការប្តូររូបិយប័ណ្ណក្នុងការបង់ទូទាត់នេះ។

ចំនួនទឹកប្រាក់ដែលត្រូវបង់នឹងត្រូវកំណត់៖

(ក) នៅថ្ងៃដែលការបង់ទូទាត់នេះត្រូវធ្វើជាក់ស្តែង រឺ

(ខ) នៅថ្ងៃដែលត្រូវបានកំណត់ដោយច្បាប់ពាក់ព័ន្ធ ប្រសិនបើការបង់ទូទាត់នេះត្រូវបានធ្វើឡើង ក្នុងករណី នៃការរំលាយ រឺ ការជំរះបញ្ជីក្រុមហ៊ុន រឺ ការចាត់ចែងចំពោះអសាធនភាពឯទៀត។

កាតព្វកិច្ចរបស់លោក-អ្នកដើម្បីធ្វើការបង់ទូទាត់នេះ គឺជាកាតព្វកិច្ចដាច់ដោយឡែកពីគ្នា និង មិនចំណុះនឹងកាតព្វកិច្ចផ្សេងៗឯទៀតណាមួយរបស់លោក-អ្នក ក្រោមកិច្ចព្រមព្រៀងនេះ រឺ ឯកសារប្រតិបត្តិការ ឯទៀតនោះទេ។

# ការជូនដំណឹង

## ១៩. ការជូនដំណឹង

*វិធីដែលយើងខ្ញុំជូនដំណឹងដល់លោក-អ្នក*

(១) ការជូនដំណឹង រឺ ការទាមទារដែលយើងខ្ញុំផ្តល់ជូនលោក-អ្នកក្រោមកិច្ចព្រមព្រៀងនេះ រឺ ក្រោមឯកសារប្រតិបត្តិការនានាឯទៀត នឹងត្រូវចុះហត្ថលេខាដោយ ប្រធានផ្នែកណាមួយរបស់ធនាគារយើងខ្ញុំ រឺ ដោយមេធាវីរបស់យើងខ្ញុំ។

(២) យើងខ្ញុំអាចផ្តល់ជូនលោក-អ្នកនូវ ការជូនដំណឹង រឺ ការទាមទារក្រោមកិច្ចព្រមព្រៀងនេះ រឺ តាមឯកសារប្រតិបត្តិការឯទៀតនោះទៅតាមអាសយដ្ឋានរបស់លោក-អ្នក រឺ ដោយផ្ញើរតាមប្រៃសណីយ៍ដោយដាក់ក្នុងស្រោមសំបុត្របង់តែមរួចស្រេច មានចុះអាសយដ្ឋានរបស់លោក-អ្នក។ អាសយដ្ឋានរបស់លោក-អ្នក គឺជាអាសយដ្ឋានដែលបានបង្ហាញនៅក្នុងលិខិតផ្តល់ឥណទាន រឺ អាសយដ្ឋានចុងក្រោយគេ របស់លោក-អ្នក ដែលយើងខ្ញុំបានកត់ត្រាទុក។

(៣) ការជូនដំណឹង រឺ ការទាមទារដែលយើងខ្ញុំបានផ្តល់ជូន លោក-អ្នក សំរាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ រឺ ឯកសារប្រតិបត្តិការនានាឯទៀតនោះ នឹងត្រូវចាត់ទុកថាបានផ្តល់ជូន ហើយលោក-អ្នកបានទទួល៖

(ក) នៅពេលដែលយើងខ្ញុំបានទុកជូន ប្រសិនបើយើងខ្ញុំបានទុកសេចក្តីជូនដំណឹង រឺ ការទាមទារនៅតាមអាសយដ្ឋានរបស់លោក-អ្នកដែលមានបញ្ជាក់នៅក្នុងអនុប្រការ (២) រឺ

(ខ) នៅថ្ងៃធ្វើការបន្ទាប់ក្រោយពីបានផ្ញើរ ប្រសិនបើយើងខ្ញុំផ្ញើរតាមប្រៃសណីយ៍ស្របតាម អនុប្រការ (២)។

*វិធី ដែលលោក-អ្នកជូនដំណឹងយើងខ្ញុំ*

(៤) ការជូនដំណឹងដែលលោក-អ្នកផ្តល់ជូនយើងខ្ញុំតាមកិច្ចព្រមព្រៀងនេះ រឺ ឯកសារប្រតិបត្តិការផ្សេងឯទៀត ត្រូវមានចុះហត្ថលេខា ដោយលោក-អ្នក រឺ ដោយអ្នកតំណាងពេញសិទ្ធិរបស់លោក-អ្នក។

(៥) លោក-អ្នកអាចជូនដំណឹងដល់យើងខ្ញុំតាមកិច្ចព្រមព្រៀងនេះ រឺ តាមឯកសារប្រតិបត្តិការផ្សេងឯទៀត ដោយយកមកអាសយដ្ឋានរបស់ យើងខ្ញុំ រឺ ផ្ញើតាមប្រៃសណីយ៍ ដោយដាក់ក្នុងស្រោមសំបុត្រដែលបង់តែមរួចស្រេចមកតាមអាសយដ្ឋានរបស់យើងខ្ញុំ។ អាសយដ្ឋានរបស់យើងខ្ញុំ គឺជាអាសយដ្ឋានដែលមាន នៅក្នុងលិខិតផ្តល់ឥណទាន រឺ អាសយដ្ឋានផ្សេងដទៃទៀតដែល យើងខ្ញុំបានជូនដំណឹងដល់លោក-អ្នកជាលាយលក្ខណ៍អក្សរ។ ការជូនដំណឹងរបស់លោក-អ្នក នឹងមានប្រសិទ្ធភាពនៅពេល ដែលយើងខ្ញុំទទួលបានការជូនដំណឹងនេះ។

(៦) ប្រសិនបើលោក-អ្នកបានជូនដំណឹងដល់យើងខ្ញុំ ដែលក្នុងអត្ថន័យជូនដំណឹងនោះបានបញ្ជាក់ រឺ បានសរសេរថា "មិនអាចកែប្រែបាន" នោះលោក-អ្នកមិនអាចលុបចោលនូវការជូនដំណឹងនោះឡើយ ហើយវាមានសុពលភាពអនុវត្តចំពោះលោក-អ្នក ចាប់ពីពេលដែលលោក-អ្នកចេញសេចក្តីជូនដំណឹងនោះ។

(៧) ទោះបីមានចែងនៅក្នុងផ្នែកផ្សេងទៀតនៃកិច្ចព្រមព្រៀងនេះ យើងខ្ញុំអាចអនុវត្តស្របតាមសេចក្តីណែនាំណាមួយ ពាក់ពន្ធ័ទៅនឹងការដកមកវិញ រឺ អ្វីផ្សេងដែល ស្ថិតនៅក្រោម រឺ មានទំនាក់ទំនងនឹងកិច្ចព្រមព្រៀងដែលមាននេះ រឺ ដែលត្រូវបានអះអាងថាបានផ្តល់មកដល់យើងខ្ញុំតាមទូរស័ព្ទ ទូរសារ រឺ មធ្យោបាយ អេឡិចត្រូនិចផ្សេងទៀត តាមរយៈផ្ទាល់មាត់ រឺ ជាលាយលក្ខណ៍អក្សរដោយលោក-អ្នក រឺ អ្នកតំណាងពេញសិទ្ធិរបស់លោក-អ្នក។ លោក-អ្នក យល់ព្រមថា ប្រសិនបើយើងខ្ញុំធ្វើនូវសកម្មភាពស្របតាមការណែនាំដែលបានផ្តល់ជូនយើងខ្ញុំតាមវិធីណាមួយនៃវិធីខាងលើនេះ សកម្មភាពរបស់យើងខ្ញុំត្រូវបានចាត់ទុកថា បានធ្វើឡើងដោយមានការអនុញ្ញាតពីលោក-អ្នក ហើយ យើងខ្ញុំមិនទទួលខុសត្រូវនូវរាល់ការខាតបង់ រឺ ការខូចខាត ដែលបានកើតឡើងបណ្តាលមកពី កំហុសឆ្គង ការខ្វះចន្លោះ រឺ ការបកស្រាយខុស ទៅលើសេចក្តីណែនាំដែលបានទទួលនោះឡើយ។ លោក-អ្នកក៏យល់ព្រមថាយើងខ្ញុំមិនទទួលខុសត្រូវនូវរាល់ ការខាតបង់ និងការខូចខាត ដែលអាចកើតឡើងបណ្តាលមកពីយើងខ្ញុំបានទទួលនូវសេចក្តីណែនាំដែលចេញពីបុគ្គលណាម្នាក់ដែលបានអះអាងថា បានធ្វើសកម្មភាពក្នុងនាមលោក-អ្នក។ យើងខ្ញុំរក្សាសិទ្ធិក្នុងការបដិសេធមិនទទួល រឺ អនុវត្តតាមសេចក្តីណែនាំបែបនោះ។

## គោលការណ៍ទូទៅ

## ២០. ការជួលអ្នកជំនាញ និង ទីប្រឹក្សាពិគ្រោះយោបល់

លោក-អ្នកយល់ព្រមថា អ្នកដែលបានជ្រើសតាំងណាមួយ ដោយធនាគារ ដែលបានទទួលកំរៃជើងសារពីខាងធនាគារ គឺត្រូវបានជួលផ្តាច់មុខសំរាប់ផលប្រយោជន៍របស់យើងខ្ញុំ មិនថាថ្លៃឈ្នួលរបស់ពួកគេទាំងនោះជាបន្ទុករបស់យើងខ្ញុំ ឬ ថ្លៃឈ្នួលនេះជាបន្ទុកដោយផ្ទាល់ រឺ ដោយប្រយោលពីខាងលោក- អ្នក។ យើងខ្ញុំ រឺ បុគ្គលិកណាមួយ របស់ធនាគារនឹងមិនទទួលខុសត្រូវចំពោះលោក-អ្នក រឺ បុគ្គលឯទៀតណាមួយ ចំពោះការខូចខាត ទំនួលខុសត្រូវ ថ្លៃចំណាយ រឺ ការចំណាយ ដែលបានកើតឡើងបណ្តាលមកពី (ដោយផ្ទាល់ ឬ ដោយប្រយោល) អ្វីដែលអ្នកជ្រើសតាំងដោយធនាគារធ្វើ រឺ មិនធ្វើ ដែលកើតចេញមកពីការ ផ្តល់សេវាចំពោះធនាគារ។

## ២១. ការលះបង់សិទ្ធ

សិទ្ធិនានាដែលយើងខ្ញុំមានក្រោមឯកសារប្រតិបត្តិការមិនអាចត្រូវបានបដិសេធចោលឡើយ លើកលែងតែមានការជូន ដំណឹងជាលាយលក្ខណ៍អក្សរពីខាងយើងខ្ញុំជូនដល់លោក-អ្នក ស្តីពីការលះបង់សិទ្ធិដោយឡែកណាមួយ។

ជាពិសេសៈ

(ក) យើងខ្ញុំមិនលះបង់ចោលសិទ្ធិណាមួយដែលយើងខ្ញុំមានពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងនេះ ដោយគ្រាន់តែយើងខ្ញុំមិនបានអនុវត្តសិទ្ធិនេះ រឺ ក៏មិនបានអនុវត្តភ្លាមៗ តាមលទ្ធភាពដែលយើងខ្ញុំអាចធ្វើទៅបាន និង

(ខ) ប្រសិនបើយើងខ្ញុំអនុវត្តសិទ្ធិ ចំនួនមួយលើក រឺ មួយផ្នែក នោះពុំមានន័យថាយើងខ្ញុំពុំអាចអនុវត្តនូវសិទ្ធិ នោះម្តងទៀត រឺ សិទ្ធិផ្សេងទៀតឡើយ។

## ២២. រូបិយប័ណ្ណ

លើកលែងតែមានខ្លឹមសារចែងផ្ទុយពីនេះក្នុងលិខិតផ្តល់ឥណទាន ការយោងដល់ ដុល្លារ $ US$ រឺ USD គឺជាការយោងដល់រូបិយប័ណ្ណស្របច្បាប់របស់សហរដ្ឋអាមេរិក។

## ២៣. ការបំលែងរូបិយប័ណ្ណរបស់សំណុំឥណទាន

ក្នុងព្រឹត្តិការណ៍ដែលប្រាក់ដុល្លារសហរដ្ឋអាមេរិកចុះថ្លៃធៀបទៅនឹងប្រាក់រៀលខ្មែរ រឺ ប្រសិនបើរាជរដ្ឋាភិបាលកម្ពុជា បង្កើតនូវការគ្រប់គ្រងរូបិយប័ណ្ណដែលដាក់កំរិត រឺ ទប់ស្កាត់ការទិញប្រាក់ដុល្លារសហរដ្ឋអាមេរិក យើងខ្ញុំតាមឆន្ទានុសិទ្ធិ អាចបំលែងសំណុំឥណទានរបស់លោក-អ្នកទៅជាប្រាក់រៀលខ្មែរ តាមរយៈបទដ្ឋានប្រតិបត្តិការរបស់យើងខ្ញុំ ក្នុងការបំលែងរូបិយប័ណ្ណ។ យើងខ្ញុំនឹងជូនដំណឹងដល់លោក-អ្នកភ្លាមៗ ជាលាយលក្ខណ៍អក្សរ ប្រសិនបើយើងខ្ញុំសំរេចចិត្តធ្វើបែបនេះ។ យើងខ្ញុំមិនចាំបាច់ធ្វើការជូនដំណឹងជាមុនដល់លោក-អ្នកឡើយ។ យើងខ្ញុំអាចធ្វើដូចនេះ បើទោះបីជាមានកិច្ចព្រមព្រៀងពីមុនចែងផ្ទុយពីនេះក៏ដោយ។ សិទ្ធិរបស់យើងខ្ញុំក្រោមប្រការនេះ គឺជាការសិទ្ធិបន្ថែម ទៅលើសិទ្ធិផ្សេងទៀតដែលយើងខ្ញុំមានស្របតាមច្បាប់ រឺ កិច្ចព្រមព្រៀងឯទៀតណាមួយ។

## ២៤. ការប្រែប្រួលជាតំរូវការរបស់រដ្ឋាភិបាល

(១) ប្រការនេះមានប្រសិទ្ធិភាពអនុវត្ត ប្រសិនបើៈ

(ក) ក្រោយពីកាលបរិច្ឆេទនៃលិខិតផ្តល់ឥណទានៈ

(១) មានការប្រែប្រួលដែលជាតំរូវការរបស់ រដ្ឋាភិបាល រឺ ជាតំរូវការថ្មីរបស់រដ្ឋាភិបាល។

(២) មានការប្រែប្រួលលើពន្ធ រឺ ពន្ធថ្មី

(៣) ការប្រែប្រួលក្នុងការបកស្រាយលើខ្លឹមសារ នៃតំរូវការរបស់រដ្ឋាភិបាល រឺ ពន្ធ ដែលជះឥទ្ធិពលលើសំណុំឥណទាន តាមប្រភេទដែលមានកំណត់នៅក្នុងលិខិតផ្តល់ឥណទាន និង

(ខ) តាមទស្សនៈរបស់យើងខ្ញុំ ឥទ្ធិពលនៃការប្រែប្រួលទាំងនេះ ដោយផ្ទាល់ រឺ ប្រយោលៈ

(១) បង្កើននូវថ្លៃចំណាយចំពោះយើងខ្ញុំក្នុងការផ្តល់ រឺ ថែរក្សាសំណុំឥណទាន រឺ សំរាប់ការផ្តល់ប្រាក់ក្រោមសំណុំឥណទាន រឺ

(២) កាត់បន្ថយនូវអត្រាជាក់ស្តែងលើចំណូលរបស់យើងខ្ញុំ (មិនថាលើដើមទុន ទ្រព្យសកម្ម ប្រាក់បញ្ញើរ រឺ អ្វីផ្សេងពីនេះ) លើសំណុំឥណទាន។

សំរាប់គោលបំណងនៃប្រការនេះ "ពន្ធ" រាប់បញ្ចូលទាំងពន្ធគយនានា តែមិនរាប់បញ្ចូល ពន្ធលើប្រាក់ចំណូលសុទ្ធរបស់យើងខ្ញុំ ក្នុងប្រតិបត្តិការធម្មតានៃអាជីវកម្មរបស់យើងខ្ញុំទេ។

(២) លោក-អ្នកយល់ព្រមទូទាត់ដល់យើងខ្ញុំ តាមការទាមទារ នូវទឹកប្រាក់ដែលបានគណនាដោយយើងខ្ញុំ ថាចាំបាច់ក្នុងការទូទាត់ប៉ះប៉ូវ សំរាប់ការកើនថ្លៃចំណាយ រឺ ការថយចុះអត្រាចំណូល។ ទឹកប្រាក់ដែលត្រូវបង់ នឹងត្រូវបានគណនាដោយយើងខ្ញុំ គិតចាប់ពីថ្ងៃដែលយើងខ្ញុំបានទទួល រងនូវថ្លៃចំណាយ រឺ ទទួលរងនូវការ ធ្លាក់ចុះនៃអត្រាចំណូលជាលើកដំបូង។

## ២៥. ការប្រែប្រួលនៃច្បាប់

ប្រសិនបើយើងខ្ញុំផ្តល់ជូនលោក-អ្នកនូវសេចក្តីជូនដំណឹងថា តាមការវិនិច្ឆ័យរបស់យើងខ្ញុំ វាបានក្លាយជាអំពើខុសច្បាប់នៅក្នុងយុត្តាធិការណាមួយ រឺ មិនអាចអោយយើងខ្ញុំ បន្តផ្តល់សំណុំឥណទានជូនលោក-អ្នក នោះកាតព្វកិច្ចរបស់យើងខ្ញុំទាក់ទងទៅនឹងសំណុំឥណទាន គឺត្រូវចប់ តាមរយៈការជូនដំណឹងនោះ។ ស្ថានភាពបែបនេះអាចកើតឡើងក្នុងករណីដែលៈ

(ក) មានការប្រែប្រួលនៃតំរូវការរបស់រដ្ឋាភិបាល រឺ មានតំរូវការថ្មីរបស់រដ្ឋាភិបាល

(ខ) មានការប្រែប្រួលនៃច្បាប់ជាលាយលក្ខណ៍អក្សរ រឺ មិនមែនជាលាយលក្ខណ៍អក្សរ រឺ ច្បាប់ថ្មី រឺ

(គ) មានការប្រែប្រួលក្នុងការបកស្រាយ រឺ ការអនុវត្ត តាមការតំរូវរបស់រដ្ឋាភិបាល រឺ ច្បាប់។

## ២៦. ច្បាប់ និង យុត្តាធិការ

(១) កិច្ចព្រមព្រៀងនេះ ស្ថិតក្រោមអនុភាពច្បាប់ដែលមានជាធរមានក្នុងព្រះរាជាណាចក្រកម្ពុជា។

(២) លើកលែងតែយើងខ្ញុំធ្វើការជ្រើសរើសផ្សេងពីនេះ ជំលោះ វិវាទ រឺ ការតវ៉ានានា ទាក់ទងនឹងឯកសារប្រតិបត្តិការនេះ ត្រូវតែដោះស្រាយដោយមជ្ឈត្តកម្មនៅប្រទេសសិង្ហបូរី ស្របតាម វិធានមជ្ឈត្តកម្ម UNCITRAL ដែលកំពុងស្ថិតនៅជាធរមានបច្ចុប្បន្ន។ សំរាប់គោលបំណងនេះៈ

(ក) សមត្ថកិច្ចតែងតាំងត្រូវតែជាប្រធាន (Chairman) ឬអនុប្រធាន (Deputy Chairman) របស់មជ្ឈមណ្ឌល មជ្ឈត្តកម្មអន្តរជាតិ សិង្ហបូរី [Singapore International Arbitration Centre (SIAC)] ។ មជ្ឈត្តកម្មនេះត្រូវតែចាត់ចែងដោយ SIAC ស្របតាមវិធានអនុវត្ត និងបទបញ្ជារបស់ខ្លួន។

(ខ) ចំនួនរបស់មជ្ឈត្តករគឺ ១ នាក់។

(គ) ភាសាដែលត្រូវប្រើក្នុងដំណើរការមជ្ឈត្តកម្ម គឺ ភាសាអង់គ្លេស (លើកលែងតែបានព្រមព្រៀងផ្សេងពីនេះ ដោយធនាគារ) ។

ប្រសិនបើយើងខ្ញុំជ្រើសរើសបញ្ជូនជំលោះណាមួយទៅមជ្ឈត្តកម្ម ស្របតាមប្រការនេះ វិធាននៃមជ្ឈត្តកម្ម ដំណើរការនៃមជ្ឈត្តកម្ម រឺ សេចក្តីសំរេចរបស់អង្គមជ្ឈត្តករ ដែលត្រូវបានតែងតាំងឡើងក្រោមប្រការនេះ មិនត្រូវមានការជំទាស់ការប្រឆាំង រឺ បណ្តឹងឧទ្ធរណ៍ រឺ ការតវ៉ាតាមហេតុផលណាមួយដែលស្ថិត ក្រោមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាឡើយ។ សេចក្តីសំរេចរបស់អង្គមជ្ឈត្តកម្មត្រូវតែចុះបញ្ជី ក្នុងព្រះរាជាណាចក្រកម្ពុជាស្របតាមច្បាប់ស្តីពីការអនុម័ត្ត និងអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីការទទួលស្គាល់សេចក្តីបង្គាប់របស់មជ្ឈត្តកម្មបរទេស។ សេចក្តីបង្គាប់នេះត្រូវមានអនុភាពអោយគូភាគី អនុវត្តស្របតាមខ្លឹមសារដែលមានចែង។

(៣) ទោះជាមានចែងក្នុង អនុប្រការ (២) ក៏ដោយ ប្រសិនបើយើងខ្ញុំចង់ជ្រើសរើសយើងខ្ញុំ និង លោក-អ្នកនឹងដាក់ខ្លួនអោយស្ថិតនៅក្រោមយុត្តាធិការមិនដាច់ខាតនៃតុលាការរបស់ព្រះរាជាណាចក្រកម្ពុជា។

## ២៧. សំណុំឥណទានដែលកំពុងមានជាធរមាន (សំណុំឥណទានដែលមានស្រាប់ ឬ បច្ចុប្បន្ន)

*កិច្ចព្រមព្រៀងនេះមានប្រសិទ្ធិភាពលើសំណុំឥណទាន ដែលកំពុងមានជាធរមាន*

(១) ប្រការនេះអនុវត្តតែក្នុងករណីដែលយើងខ្ញុំបានរៀបចំសំណុំឥណទានជូនលោក-អ្នករួចជាស្រេចហើយ ទៅតាមកាលបរិច្ឆេទនៃលិខិតផ្តល់ឥណទាន។

(២) ការរៀបចំអោយមានសំណុំឥណទានដែលយើងខ្ញុំបានរៀបចំជូនលោក-អ្នកតាមកាលបរិច្ឆេទនៃលិខិតផ្តល់ឥណទាន រួមបញ្ចូលទាំងលក្ខខណ្ឌនានាក្នុងការផ្តល់ជូនសំណុំឥណទាននោះ (ការរៀបចំដែលមានជាធរមាន) បន្តរហូតដល់ចំណុចទាំងពីរដូចខាងក្រោមនេះកើតឡើងៈ

(ក) លោក-អ្នកផ្តល់ស៊ីការលើលិខិតផ្តល់ឥណទានរបស់យើងខ្ញុំ និង

(ខ) អ្វីៗគ្រប់យ៉ាងដែលត្រូវធ្វើ មុនពេលដែលយើងខ្ញុំរៀបចំសំណុំឥណទានជូនស្របតាមលិខិតផ្តល់ឥណទាននោះ បានធ្វើរួចរាល់ តាមការវាយតំលៃរបស់យើងខ្ញុំ។

ដោយឡែក រហូតទាល់តែចំណុចដែលបានរៀបរាប់ទាំងពីរខាងលើនេះត្រូវបានបំពេញ យើងខ្ញុំនៅតែអាចអនុវត្តសិទ្ធិដែលយើងខ្ញុំមានក្រោមការរៀបចំដែលមានជាធរមាន រួមទាំងសិទ្ធិក្នុងការបញ្ចប់ រឺ កែប្រែទៅលើលក្ខខណ្ឌនៃសំណុំឥណទានដែលកំពុងមានជាធរមាន។

**កំណត់សំគាល់:** *លិខិតផ្តល់ឥណទាននោះប្រាប់លោក-អ្នកនូវអ្វី ដែលលោក-អ្នកត្រូវធ្វើ ដើម្បីផ្តល់ស៊ីការលើលិខិតផ្តល់ឥណទានរបស់យើងខ្ញុំ។ ប្រការ ៤ បានដាក់ចេញនូវចំណុចដែលត្រូវធ្វើ មុនពេលដែលយើងខ្ញុំរៀបចំសំណុំឥណទានផ្តល់ជូនលោក-អ្នក។ ចំណុចផ្សេងទៀតអាចនឹងត្រូវបានកំណត់នៅក្នុងលិខិតផ្តល់ឥណទាននោះ។*

(៣) នៅពេលចំនុចទាំងពីរដែលបានយោងនៅក្នុង អនុប្រការ (២)(ក) និង (ខ) បានកើតឡើង លក្ខខណ្ឌនានារបស់សំណុំឥណទានដែលកំពុងមានជាធរមាន នឹង ចាប់ពីពេលនោះតទៅ ជាលក្ខខណ្ឌនានាដូចមានចែង និងមានយោងនៅក្នុងកិច្ចព្រមព្រៀងនេះ។ ប៉ុន្តែៈ

(ក) កិច្ចព្រមព្រៀងនេះមិនអាចជំនួសដល់កិច្ចធានា ការធានា សមត្ថកិច្ច អំណាច រឺ សំណង ដែលនៅមានជាធរមាន នៅកាលបរិច្ឆេទនៃលិខិតផ្តល់ឥណទាននេះ (ឯកសារទាំងនេះនិងខចែងរបស់វា គឺមិនអាចធ្វើអោយគ្មានប្រសិទ្ធិភាពដោយមធ្យោបាយណាមួយឡើយ) និង

(ខ) ប្រសិនបើលិខិតផ្តល់ឥណទានចែងថា លក្ខខណ្ឌមួយចំនួន រឺ ទាំងអស់នៃសំណុំឥណទានបច្ចុប្បន្ន គឺមិនអោយមានការផ្លាស់ប្តូរលក្ខខណ្ឌទាំងនោះនឹងមិនត្រូវបានជំនួសដោយលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះទេ។

## ២៨. ការរួមបញ្ចូលគណនី

យើងខ្ញុំអាច នៅពេលណាមួយ បញ្ចូល បូកសរុប រំលាយបញ្ចូល រឺ ដាក់សមតុល្យឥណទានណាមួយ ក្នុងគណនីណាមួយរបស់លោក-អ្នក រឺ ទឹកប្រាក់ណាមួយដែលបានមកដល់យើងខ្ញុំ ដោយវិធីសាស្រ្តទូទាត់-កាត់កង សិទ្ធិឃាត់ទុក រឺ បណ្តឹងតប ចំពោះការទូទាត់ដែលបានដល់កំណត់សង រឺ នឹងត្រូវដល់កំណត់សង និង ត្រូវទូទាត់ដោយលោក-អ្នកមកកាន់យើងខ្ញុំ ក្រោមឯកសារប្រតិបត្តិការណាមួយ។ ប្រសិនបើយើងខ្ញុំ ធ្វើចំណុចណាមួយនៃចំណុចទាំងនេះ យើងខ្ញុំនឹងជូនដំណឹងដល់លោក-អ្នកជាលាយលក្ខណ៍អក្សរ។ យើងខ្ញុំអាចធ្វើចំណុចណាមួយនៃចំណុចទាំងនេះ បើទោះបីជាកិច្ចព្រមព្រៀងពីមុនណាមួយចែងផ្ទុយពីនេះក៏ដោយ។ លោក-អ្នកអនុញ្ញាតិឱ្យយើងខ្ញុំធ្វើអ្វីៗក្នុងនាមលោក-អ្នក អោយតែជាការចាំបាច់សំរាប់យើងខ្ញុំ ដើម្បីអាចអនុវត្តចំណុចណាមួយនៃចំណុចទាំងនេះ។ សិទ្ធិរបស់យើងខ្ញុំក្រោមប្រការនេះ គឺជាសិទ្ធិបន្ថែមទៅលើ សិទ្ធិឯទៀត ដែលយើងខ្ញុំមានស្របតាមច្បាប់ រឺ កិច្ចព្រមព្រៀងឯទៀតណាមួយ។

## ២៩. ការព្រមព្រៀងចំពោះព័ត៌មានផ្ទាល់ខ្លួន

លោក-អ្នកយល់ព្រមអោយធនាគារបើកចំហរព័តិមានផ្ទាល់ខ្លួនរបស់លោក-អ្នក ដល់៖

(ក) អង្គការ រឺ ក្រុមហ៊ុន ណាមួយដែលកំពុងមានការរៀបចំ រឺ ជា សម្ព័ន្ធភាពសហការជាមួយធនាគារ

(ខ) អ្នកផ្តល់សេវាកម្មណាមួយដែលធនាគារបានជួលឱ្យអនុវត្ត រឺ អោយជួយបំពេញមុខងារ និងសកម្មភាព របស់ខ្លួន

(គ) អ្នកផ្តល់កិច្ចធានា អ្នកទទួលសិទ្ធិ រឺ អ្នកដែលទទួលបានការផ្ទេរសិទ្ធិ រឺ នរណាម្នាក់ ដែលកំពុងទទួលបានការគិតគូរអោយក្លាយ ទៅជាជនណាមួយខាងលើនេះ និង

(ឃ) ការិយាល័យឥណទាន រឺ ការិយាល័យបញ្ជីការប្រហាក់ប្រហែល ក្នុងគោលបំណងអនុវត្តការត្រួតពិនិត្យឥណទាន និង

(ង) កាលណាតំរូវដោយច្បាប់។

## ៣០. ការព្រមព្រៀងផ្នែកហិរញ្ញវត្ថុ

ប្រសិនបើលិខិតផ្តល់ឥណទានរបស់លោក-អ្នកបានចែងពីការព្រមព្រៀងផ្នែកហិរញ្ញវត្ថុ ដែលលោក-អ្នកត្រូវតែគោរពតាម នោះនិយមន័យ រូបមន្តអនុបាត និង វិធាននៃការបកស្រាយដូចតទៅនេះ នឹងយកមកអនុវត្ត៖

(១) និយមន័យ

**"ទ្រព្យអកម្មសរុប"** មានន័យថា ទ្រព្យអកម្មចរន្តសរុប និងទ្រព្យអកម្មរយៈពេលវែងសរុបរបស់លោក-អ្នក និងអង្គភាពដែលបានទទួលការគ្រប់គ្រងរបស់លោក-អ្នក ដូចដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុបូកសរុប។ នេះបើតាមនិយមន័យ រួមបញ្ចូលនូវភាគហ៊ុនអាទិភាព ដែលអាចទិញត្រលប់មកវិញបាន បំណុលបន្ទាប់បន្សំ សំវិធានធន និង ភាគលាភដែលបានប្រកាស រឺ បង្គរ ប៉ុន្តែមិនទាន់បានទូទាត់។

**"មូលធនសរុប"** មានន័យថា ជាការរួមបញ្ចូលគ្នានូវមូលធន ដែលបានបោះផ្សាយ និងបានបង់បង្គ្រប់ ភាគហ៊ុនអាទិភាពដែលមិនអាចទិញត្រលប់មកវិញបាន ទុនបំរុង ប្រាក់បំរុងជាទូទៅ ប្រាក់ចំណូលបំរុងទុក ប្រាក់បំរុងសំរាប់ការបំលែងជារូបិយប័ណ្ណបរទេស ផលប្រយោជន៍របស់អ្នកមានសំលេងតិច ប្រាក់ចំណេញរក្សាទុក និង ភាគហ៊ុនអាចទិញត្រលប់មកវិញ។

**"ទ្រព្យសកម្មអរូបីយសរុប"** ជាការរួមបញ្ចូលគ្នានូវផលប្រយោជន៍ពីការអនុគ្រោះពន្ធចំពោះប្រាក់ចំណេញនាពេលអនាគត ការចំណាយដើមគ្រា ការបង់ទូទាត់ប្រាក់ជាមុន កេរ្តិ៍ឈ្មោះជំនួញ ប្រកាសនីយប័ត្រតក្កកម្ម /ពាណិជ្ជសញ្ញា /អាជ្ញាប័ណ្ណ/ម៉ាកយីហោ និងទ្រព្យអរូបីយដទៃទៀត។ ដើម្បីគណនាអនុបាតនេះ ធនាគារអាចធ្វើការចាត់ជាថ្នាក់សារជាថ្មីនូវទ្រព្យសកម្មមួយចំនួនជា"ទ្រព្យអរូបីយ"។ យើងខ្ញុំនឹងជូនដំណឹងដល់លោក-អ្នក ប្រសិនបើមានករណីនេះកើតឡើង។

**"មូលធនជាក់ស្តែង"** មានន័យថា មូលធនសរុប ដក ទ្រព្យសកម្មអរូបីយសរុប។

**"ចំណាយលើការប្រាក់"** មានន័យថា ការចំណាយលើការប្រាក់ទាំងអស់ រួមទាំងចំណាយចំពោះការប្រាក់នៃសំណុំឥណទាន ពីក្នុងរង្វង់ក្រុមហ៊ុនគ្នាឯង ពីអភិបាល បំណុលពីម្ចាស់ក្រុមហ៊ុន និងពីភាគទុនិក។

**"បំណុលបន្ទាប់បន្សំរយៈពេលវែង"** មានន័យថា បំណុលទាំងឡាយណា ដែលចេញមកពី អភិបាល/ ម្ចាស់/ម្ចាស់ភាគហ៊ុន/ក្រុមហ៊ុនរង និងក្រុមហ៊ុនពាក់ព័ន្ធ ដែលបានព្យួរ រឺ ដាក់អោយទៅជាបន្ទាប់បន្សំ ក្រោមកិច្ចធានារបស់ធនាគារ ដើម្បីបំពេញតាមការចង់បានរបស់ធនាគារ ទៅតាមកំរិតនៃទឹកប្រាក់ដែលបានព្យួរ រឺ ដាក់អោយទៅជាបន្ទាប់បន្សំ។

**"EBITDA"** មានន័យថា ប្រាក់ចំណេញ(ខាត) សុទ្ធសរុប មុននឹងដកការប្រាក់ពន្ធ ការកាត់រំលោះ និងការសងរំលោះ។

**"លទ្ធភាពទូទាត់បំណុលសរុប"** មានន័យថា ការទូទាត់ប្រាក់ដើម បូកបន្ថែមថ្លៃការប្រាក់ បូកជាមួយនឹងកំរៃដែលកំពុងមាន។

(២) រូបមន្តអនុបាត

**អនុបាតសាច់ប្រាក់ងាយស្រួល** (Current Ratio)

ទ្រព្យសកម្មចរន្តសរុប
/ ទ្រព្យអកម្មចរន្តសរុប

**អនុបាតលទ្ធភាពទូទាត់ការប្រាក់** (Interest Cover Ratio)

ប្រាក់ចំណេញសុទ្ធ (ខាត) មុនបង់ ការប្រាក់ និងពន្ធ
/ ការចំណាយលើការប្រាក់សរុប

**អនុបាតបំណុលធៀបនឹងមូលនិធិភាគទុនិក** (Adjusted Gearing Ratio)

ទ្រព្យអកម្មសរុប – បំណុលបន្ទាប់បន្សំរយៈពេលវែង
/ មូលធនជាក់ស្តែង + បំណុលបន្ទាប់បន្សំរយៈពេលវែង

**អនុបាតលទ្ធភាពទូទាត់បំណុល** (Debt Service Ratio)

ប្រាក់ប្រតិបត្តិសុទ្ធ (EBITDA)
/ បំណុលសរុប

(៣) **ការបកស្រាយ**

លោក-អ្នកយល់ព្រមថា ការបកស្រាយ និងការសាកល្បងនៃ ការព្រមព្រៀងផ្នែកហិរញ្ញវត្ថុដែលមានចែងនៅក្នុងលិខិតផ្តល់ឥណទាននឹងត្រូវបានអនុវត្ត អោយស្របតាមវិធានដែលកំណត់ តាមឆន្ទានុសិទ្ធិដាច់ខាតរបស់ធនាគារ និងទស្សនទានគណនេយ្យ បទដ្ឋាន និងការតំរូវអោយប្រកាសជាចំហរទៅ តាមបទដ្ឋានគណនេយ្យកម្ពុជា។

## ការបកស្រាយកិច្ចព្រមព្រៀង

## ៣១. អត្ថន័យរបស់ពាក្យ និងសំនួនសេចក្តី

(១) នៅក្នុងកិច្ចព្រមព្រៀងនេះ និង (ជាកម្មវត្ថុនៃកថាខណ្ឌទី ៤ ខាងក្រោម) នៅក្នុងលិខិតផ្តល់ឥណទានណាមួយ លើកលែងតែក្នុងបរិបទនោះ តំរូវផ្សេង ពីនេះ៖

"**ព្រឹត្តិការណ៍ពន្លឿន**" មានន័យថា ជាព្រឹត្តិការណ៍ដែលនឹងតំរូវអោយលោក-អ្នកសង និងត្រូវសងមកដល់យើងខ្ញុំភ្លាម១ ក្រោមកិច្ចព្រមព្រៀងដទៃ ទៀតដែលលោក-អ្នកមានជាមួយយើងខ្ញុំ ប្រសិនបើព្រឹត្តិការណ៍នោះកើតឡើង។

"**សិទ្ធិចាត់ចែងប្រតិបត្តិការគណនី**" មានន័យថា ជាសិទ្ធិមួយដែលប្រគល់អោយអ្នកតំណាងពេញសិទ្ធិ របស់លោក-អ្នក ដែលដាក់ជូនយើងខ្ញុំក្នុង ទំរង់មួយ ដែលយើងខ្ញុំអាចទទួលយកបាន។

"**អត្រាការប្រាក់មូលដ្ឋានរបស់ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់**" មានន័យថា អត្រាការប្រាក់ដែលបានកំណត់ពីពេលមួយទៅពេលមួយ ដោយធនាគារ ដើម្បី ជាកំរិត វាស់ស្ទង់សមរម្យទៅលើអត្រាការប្រាក់ដែលកំពុងមានជាធរមាន ហើយនឹងបោះពុម្ពផ្សាយដោយធនាគារ ពីពេលមួយទៅពេលមួយ។

"**កិច្ចព្រមព្រៀង**" មានន័យថា កិច្ចព្រមព្រៀងដែលត្រូវបានបង្កើតឡើងតាមរយៈការផ្តល់ស្វីការរបស់លោក-អ្នកលើ លិខិតផ្តល់ឥណទានរបស់យើងខ្ញុំ។

"**អ្នកតំណាងពេញសិទ្ធិរបស់លោក-អ្នក**" មានន័យថា គឺជាបុគ្គលដែលត្រូវបានប្រគល់សិទ្ធិដោយលោក-អ្នក នៅពេលជាក់លាក់ណាមួយក្នុងការ ប្រតិបត្តិគណនីថ្មីជាងគេ ដែលលោក-អ្នកបានផ្តល់ដល់យើងខ្ញុំ ដើម្បីធ្វើសកម្មភាពក្នុងនាមលោក-អ្នកចំពោះគ្រប់រឿងរ៉ាវ កិច្ចការ និងប្រតិបត្តិការ នានាជាមួយយើងខ្ញុំ។

"**ធនាគារ**" គឺ ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់។

"**អ្នកដែលទទួលបានការតែងតាំង**" មានន័យថា អ្នកជំនាញ ឬ ទីប្រឹក្សាពិគ្រោះយោបល់ ដែលផ្តល់សេវាដល់ធនាគារ។

"**អ្នកគ្រប់គ្រង ( ឬប្រធានផ្នែក ) របស់ធនាគារ**" មានន័យថា៖

(ក) ជាបុគ្គលិករបស់យើងខ្ញុំដែលមានមុខតំណែង រឺ កំពុងធ្វើសកម្មភាពតាមមុខតំណែង ដែលឈ្មោះនៃមុខតំណែងនោះ មានពាក្យថា "អ្នក គ្រប់គ្រង" (ឬ ប្រធានផ្នែក) រឺ "គណនេយ្យករ" រឺ

(ខ) ជនណាម្នាក់ដែលយើងខ្ញុំបានតែងតាំងជាតំណាងរបស់យើងខ្ញុំ។

"**ថ្ងៃធ្វើការ**" មានន័យថា៖

(ក) គឺជាថ្ងៃដែលការិយាល័យរបស់យើងខ្ញុំបើកដំណើរការ ដែលជាទីកន្លែងដែលការទូទាត់ រឺ ការដកប្រាក់នោះត្រូវបានធ្វើឡើង សំរាប់ការទូទាត់ រឺ ការដកប្រាក់ដែលបានតំរូវក្រោមកិច្ចព្រមព្រៀងនេះ ដែលនឹងត្រូវធ្វើនៅទីកន្លែងក្រៅពីរាជធានីភ្នំពេញ

(ខ) ពុំនោះទេ គឺជាថ្ងៃដែលទីស្នាក់ការកណ្តាលរបស់យើងខ្ញុំបើកទ្វារធ្វើអាជីវកម្មធនាគារទូទៅ។

**"ការផ្លាស់ប្តូរឥណទាន"** ការផ្លាស់ប្តូរនៃឥណទានកើតមានឡើង ប្រសិនបើ ក្រោយពីការវាយតំលៃសារជាថ្មីលើឥណទានៈ

(ក) យើងខ្ញុំគ្រាន់តែអាចផ្តល់ជូននូវសំណុំឥណទានណាមួយ រឺ ច្រើន តាមលក្ខខណ្ឌខុសពីលក្ខខណ្ឌដែលយើងខ្ញុំធ្លាប់បានផ្តល់ពីមុន នៅពេលកំពុងវាយតំលៃសារជាថ្មី នៃឥណទាននោះ រឺ

(ខ) យើងខ្ញុំពុំអាចផ្តល់នូវសំណុំឥណទានដោយឡែកណាមួយ។

**"ការផ្លាស់ប្តូរនៃការគ្រប់គ្រង"** មានន័យថា ដោយមិនមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមុនពីយើងខ្ញុំ ការគ្រប់គ្រងដែលមានសុពលភាពរបស់លោក- អ្នក រឺ អ្នកផ្តល់កិច្ចធានាណាមួយ រឺ ក្រុមហ៊ុនបុត្រសម្ព័ន្ធណាមួយរបស់លោក-អ្នក រឺ របស់ពួកគេតាមការវិនិច្ឆ័យរបស់យើងខ្ញុំ ត្រូវបានកែប្រែជាសារវ័ន្ត ខុសពីកំរិតដែលមាននៅកាលបរិច្ឆេទនៃលិខិតផ្តល់ឥណទានរបស់យើងខ្ញុំ។

**"លក្ខខណ្ឌ"** ទាក់ទងនឹងសំណុំឥណទាន មានន័យថា បញ្ញត្តិ រឺ ប្រការណាមួយ នៃកិច្ចព្រមព្រៀងនេះ។

**"ថ្លៃចំណាយ"** រួមមានជាអាទិ៍ៈ

(ក) ការគិតថ្លៃ និងកំរៃជើងសាររបស់យើងខ្ញុំ

(ខ) កំរៃនានា ឬ ប្រាក់ឈ្នួល

(គ) ការចំណាយនានា

(ឃ) អាករ រឺ ពន្ធ (ឧទាហរណ៍ ការគិតថ្លៃ ប្រាក់ឈ្នួល រឺ ពន្ធណាមួយរបស់រដ្ឋាភិបាល) និង

(ង) ថ្លៃសេវាផ្នែកច្បាប់ សំរាប់កិច្ចព្រមព្រៀងនេះ រឺ ប្រតិបត្តិការនានាក្រោមកិច្ចព្រមព្រៀងនេះ។

**"ការវាយតំលៃឥណទានសារជាថ្មី"** មានន័យថា ជាការវាយតំលៃសំណុំឥណទាន ដែលធ្វើឡើងដោយយើងខ្ញុំៈ

(ក) ដោយប្រើនូវលក្ខណៈវិនិច្ឆ័យបច្ចុប្បន្នរបស់យើងខ្ញុំ សំរាប់ការវាយតម្លៃលើពាក្យស្នើសុំសំរាប់ការផ្តល់សំណុំឥណទាន និង

(ខ) ដោយចាត់ទុកដូចជាយើងខ្ញុំកំពុងធ្វើការវាយតំលៃ លើពាក្យស្នើសុំថ្មីសំរាប់ការផ្តល់ជូនសំណុំឥណទាន ដែលលោក-អ្នកដាក់ស្នើ។

**"អតិថិជន"** ទាក់ទងទៅនឹងសំណុំឥណទាន មានន័យថា បុគ្គលដែលមានឈ្មោះជាអតិថិជននៅក្នុងលិខិតផ្តល់ឥណទាន និង រួមទាំងប្រតិបត្តិករ អ្នកគ្រប់គ្រងទ្រព្យ សន្តតិជន និងអ្នកបានទទួលការផ្ទេរសិទ្ធិ របស់បុគ្គលនោះ ដែលមានការអនុញ្ញាតិទាំងឡាយ។

**"ការរំលោភលើកិច្ចព្រមព្រៀង"** លោក-អ្នកគឺរំលោភលើកិច្ចព្រមព្រៀង ប្រសិនបើមានព្រឹត្តិការណ៍នៃការរំលោភលើកិច្ចព្រមព្រៀងបានកើតឡើង។

**"កាលបរិច្ឆេទដកប្រើប្រាស់"** មានន័យថា ជាថ្ងៃដែលដកប្រើប្រាស់ រឺ ត្រូវបានស្នើអោយដកប្រើប្រាស់ ដែលត្រូវបានផ្តល់ជូនដោយលោក-អ្នក ក្រោមកិច្ចព្រមព្រៀងនេះ។

**"ការជូនដំណឹងពីការដកប្រើប្រាស់"** មានន័យថា ការជូនដំណឹងដែលបានផ្តល់ជូនដោយលោក-អ្នក ស្របតាមលក្ខខណ្ឌពិសេសសំរាប់សំណុំឥណទានដែលស្នើអោយមានការដកប្រើប្រាស់។

**"ការដកប្រើប្រាស់"** មានន័យថា ទំរង់ណាមួយនៃឥណទាន ដែលត្រូវបានផ្តល់ជូន ឬ ដែលនឹងត្រូវបានផ្តល់ជូនដល់លោក-អ្នក ក្រោមសំណុំឥណទានណាមួយនោះ។

**"ដើម្បីធ្វើការដកប្រើប្រាស់"** និង សំនួនសេចក្តីប្រហាក់ប្រហែលគ្នា មានន័យថា ដើម្បីទទួលបានការផ្តល់ហិរញ្ញវត្ថុ ក្រោមសំណុំឥណទានណាមួយ។

**"ការគ្រប់គ្រងដែលមានសុពលភាព"** នៃក្រុមហ៊ុនមួយ មានន័យថាៈ

(ក) ការគ្រប់គ្រងរបស់សមាសភាពនៃក្រុមប្រឹក្សាភិបាល នៃក្រុមហ៊ុននោះ

(ខ) ការគ្រប់គ្រងច្រើនជាងពាក់កណ្តាលនៃសិទ្ធិបោះឆ្នោត ដែលភ្ជាប់ទៅនឹងភាគហ៊ុនរបស់ក្រុមហ៊ុននោះ រឺ

(គ) ការគ្រប់គ្រងច្រើនជាងពាក់កណ្តាលនៃភាគហ៊ុនដែលដាក់ចេញដោយក្រុមហ៊ុននោះ (ដោយមិនរាប់បញ្ចូលភាគហ៊ុនណាមួយ ដែលមិនមានសិទ្ធិក្នុងការចូលរួមលើសពីទឹកប្រាក់ដែលបានបញ្ជាក់ នៅក្នុងការបែងចែកនៃប្រាក់ចំណេញ រឺ ដើមទុន) និងរួមបញ្ចូលផងដែរនូវការទទួលបានតាមមធ្យោបាយណាមួយ ដោយបុគ្គលដែលមានផលប្រយោជន៍ក្នុងភាគហ៊ុននៅក្នុងក្រុមហ៊ុននោះ ដែលមានចំនួនគ្រប់គ្រាន់ដើម្បីអនុញ្ញាតអោយបុគ្គលនោះអនុវត្តការគ្រប់គ្រងនោះតែម្នាក់ឯង រឺ រួមគ្នាដូចមានយោងក្នុងចំនុច(ក) (ខ) ឬ (គ) នៃនិយមន័យនេះ។

**"ច្បាប់បរិស្ថាន"** មានន័យថា ច្បាប់ណាមួយដែលមានគោលបំណងការពារបរិស្ថានពីការបំពុលដោយរាប់ទាំងការបំពុល ដែលទាក់ទងនឹងខ្យល់អាកាស ទឹក សំលេង រឺ សារធាតុគីមី (និងការកែប្រែណាមួយចំពោះ រឺ ការដាក់ជំនួសច្បាប់ណាមួយ) និងការបំពុលផ្សេងៗទៀត។

**"ការធានាអះអាងរក្សាបរិស្ថាន"** មានន័យថាការធានាអះអាងនៅក្នុង ប្រការ ៥(១)(ដ) ។

**"ព្រឹត្តិការណ៍នៃការរំលោភលើកិច្ចព្រមព្រៀង"** មានន័យថា កាលៈទេសៈទាំងឡាយដែលបានរៀបរាប់ក្នុង ប្រការ ១៤ នៃលក្ខខណ្ឌទូទៅទាំងនេះ។

**"សំណុំឥណទាន"** មានន័យថាសំណុំឥណទាននីមួយៗ រឺ គ្រប់សំណុំឥណទាន ដែលរៀបចំឡើងសំរាប់ផ្តល់ជូនលោក-អ្នក ក្រោមកិច្ចព្រមព្រៀងនេះ។

**"របាយការណ៍ហិរញ្ញវត្ថុ"** គឺៈ

(ក) **របស់ក្រុមហ៊ុន** មានន័យថាៈ

(១) តារាងតុល្យការរបស់ក្រុមហ៊ុន និងរបាយការណ៍ចំណេញ ខាត នៃឆ្នាំហិរញ្ញវត្ថុនីមួយៗ និង

(២) របាយការណ៍ហិរញ្ញវត្ថុឯទៀតណា ដែលតំរូវអោយមានការរៀបចំតាមច្បាប់ណាមួយ នៃកន្លែងចុះបញ្ជីក្រុមហ៊ុននោះ។

របាយការណ៍ហិរញ្ញវត្ថុត្រូវតែមានការបញ្ជាក់ដោយអភិបាលរបស់ក្រុមហ៊ុនថា បានផ្តល់ពីភាពពិតប្រាកដ និងត្រឹមត្រូវអំពី៖
(ក) ស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននៅដំណាច់ឆ្នាំហិរញ្ញវត្ថុនោះ និង
(ខ) លទ្ធផលនៃកិច្ចប្រតិបត្តិការរបស់ក្រុមហ៊ុនសំរាប់ឆ្នាំហិរញ្ញវត្ថុនោះ។

(ខ) **របស់រូបវន្តបុគ្គល** មានន័យថា ជារបាយការណ៍ស្ថានភាពហិរញ្ញវត្ថុដែលបានចុះហត្ថលេខាដោយបុគ្គលនោះ ក្នុងទំរង់មួយដែលបំពេញតាមតំរូវការរបស់យើងខ្ញុំ ដោយមានរៀបរាប់ទ្រព្យសកម្ម និង ទ្រព្យអកម្ម បច្ចុប្បន្នរបស់បុគ្គលនោះ ព្រមទាំងមាន ចែងពីតំរោងថវិកាចំណូល និង ចំណាយសំរាប់ឆ្នាំបន្ទាប់ និង

(គ) **របស់ក្រុមហ៊ុនសហកម្មសិទ្ធិ** មានន័យថា គឺរបាយការណ៍ទាំងឡាយរបស់ក្រុមហ៊ុនសហកម្មសិទ្ធិ ដែលត្រូវបានបញ្ជាក់ដោយសហកម្មសិទ្ធិករ ២រូប ថាបានផ្តល់នូវភាពពិតប្រាកដ និងត្រឹមត្រូវ អំពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសហកម្មសិទ្ធិនៅដំណាច់ឆ្នាំហិរញ្ញវត្ថុនោះ ដោយមានភ្ជាប់មកជាមួយនូវច្បាប់ចតចំលងនៃឯកសារបង់ពន្ធចំណូលរបស់ក្រុមហ៊ុនសហកម្មសិទ្ធិ សំរាប់ឆ្នាំហិរញ្ញវត្ថុពីមុន១នោះ។

"**តតិយជនរក្សាទ្រព្យ**" (garnishee) មានន័យថាបុគ្គល (រួមទាំងយើងខ្ញុំ) ដែល៖
(ក) កាន់កាប់ រឺ អាចកាន់កាប់ប្រាក់សំរាប់លោក-អ្នក រឺ ក្នុងគណនីរបស់លោក-អ្នក រឺ
(ខ) ជំពាក់ រឺ អាចជំពាក់ប្រាក់លោក-អ្នក

"**ការជូនដំណឹងដល់តតិយជនរក្សាទ្រព្យ**" មានន័យថាជាការជូនដំណឹង ដែលត្រូវបានផ្តល់ជូនដល់តតិយជនរក្សាទ្រព្យ តាមច្បាប់ណាមួយ ដោយតំរូវអោយតតិយជនរក្សាទ្រព្យ នោះធ្វើការបង់ទូទាត់ទឹកប្រាក់ ស្របតាមការជូនដំណឹង ដោយមិនគិតពីការណែនាំផ្ទុយណាមួយ ដែលលោក-អ្នកអាចនឹងផ្តល់ជូនដល់ តតិយជនរក្សាទ្រព្យនោះទេ។

"**ភ្នាក់ងាររដ្ឋាភិបាល**" មានន័យថា៖
(ក) រដ្ឋាភិបាល រឺ ក្រសួង នាយកដ្ឋាន អាជ្ញាធរ រឺ អង្គភាព ដទៃទៀតរបស់រដ្ឋាភិបាល
(ខ) មន្ត្រី របស់រដ្ឋាភិបាល ស្ថាប័នស្វយ័ត រឺ ស្ថាប័នតុលាការ
(គ) បុគ្គល ដែលទទួលបន្ទុកខាងរដ្ឋបាលច្បាប់ (មិនថាដោយមានស្វ័យភាព រឺ អត់)។

"**ការតំរូវ ( រឺ តំរូវ ) របស់រដ្ឋាភិបាល**" មានន័យថា ច្បាប់ រឺ សេចក្តីណែនាំ រឺ ការតំរូវ (រឺ តំរូវការ) មិនថាមានអំណាចផ្លូវច្បាប់ រឺគ្មានដែលត្រូវបានដាក់ឱ្យអនុវត្ត ដោយ ធនាគារជាតិនៃកម្ពុជា រឺ ដោយភ្នាក់ងាររដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជា រឺ អង្គភាពប្រហាក់ប្រហែលគ្នានៅបរទេស។
ឧទាហរណ៍: ចំពោះការតំរូវរបស់រដ្ឋាភិបាលរួមមាន ការតំរូវចំពោះប្រាក់បំរុង ការតំរូវចំពោះដើមទុនអប្បបរមា និង មូលនិធិផ្ទាល់សុទ្ធ ការតំរូវប្រាក់តំកល់ពិសេស ការកំរិតការខ្ចីប្រាក់ ការដាក់កំណត់លើអត្រាបំណុលធៀប និង ដើមទុន (Gearing Constraint) និងវិធាននៃការកំណត់ដើមទុន។

"**សេចក្តីណែនាំ**" រួមបញ្ចូលនូវ៖
(ក) សេចក្តីជូនដំណឹង
(ខ) សំណើ
(គ) ស្ទីការ (រួមបញ្ចូលទាំង ស្ទីការលើសំនុំឥណទានដែលមានការកែប្រែបន្ថែម)។

"**ច្បាប់**" រួមមាន ច្បាប់ ព្រះរាជក្រឹត្យ រឺ ក្រឹត្យ អនុក្រឹត្យ ប្រកាស សេចក្តីសំរេច សារាចរ រឺ បទបញ្ជាណាមួយ ដែលចេញដោយរាជរដ្ឋាភិបាលកម្ពុជា។

"New Basel Capital Accord" គឺជាស្តង់ដារអនុវត្តអន្តរជាតិ ដែលត្រូវបានបង្កើតឡើង ដើម្បីពង្រឹងនូវវិធីសាស្ត្រដែលធនាគារទាំងឡាយប្រើ ដើម្បីវាស់វែងនូវការតំរូវដើមទុន ជាលក្ខណៈផ្ទៃក្នុងរបស់ធនាគារ (ដោយគិតគូរដល់ហានិភ័យនៃផលប័ត្រឥណទានរបស់ធនាគារទាំងនោះ)។

"**អ្នកផ្តួចផ្តើម រឺ ជើងសារ**" មានន័យថា តតិយជនដែលត្រូវបានទទួលស្គាល់ដោយធនាគារ ឱ្យណែនាំអតិថិជនថ្មីឱ្យដល់យើងខ្ញុំ។ អ្នកផ្តួចផ្តើម រឺ ជើងសារ មិនមែនជាភ្នាក់ងាររបស់ធនាគារទេ។

"**លិខិតផ្តល់ឥណទាន ( សំណើរ ) របស់យើងខ្ញុំ**" មានន័យថា សំណើរបស់យើងខ្ញុំនៅក្នុងលិខិតផ្តល់ឥណទាន។

"**ប្រាក់មិនទាន់សង**" សំរាប់សំណុំឥណទានណាមួយ មានន័យថា ទឹកប្រាក់ដែលលោក-អ្នកជំពាក់ពិតប្រាកដ រឺ អាចនឹងជំពាក់យើងខ្ញុំ ក្រោមសំណុំឥណទានដោយរួមបញ្ចូលទាំងការប្រាក់ និងថ្លៃចំណាយ (ដោយគ្មានបានផ្លាស់ប្តូរពីរូបិយប័ណ្ណដើម)។

"**កិច្ចធានាផ្សេង១**" មានន័យថា កិច្ចសន្យាដាក់បញ្ចាំ (ហ៊ីប៉ូតែក) (Mortgage) ការដាក់បញ្ចាំហ៊ុន (Pledge) ការដាក់ទ្រព្យបញ្ចាំ (Antichrese) ការដាក់ធានា (Gage) សិទ្ធិឃាត់ទុក (Lien) ការដាក់បន្ទុក (Charge) រឺ ការផ្ទេរសិទ្ធិ រឺ ការរៀបចំឯទៀតណាមួយជាមួយនឹងបុគ្គល អង្គភាពផ្សេងក្រៅពីធនាគារ (រួមទាំង ការរៀបចំ សំរាប់ការទូទាត់-កាត់កងណាមួយ) ដែលធ្វើអោយមានប្រសិទ្ធិភាពប្រហាក់ប្រហែលគ្នានឹងការផ្តល់កិច្ចធានាផ្សេង ពីកិច្ចធានាណាមួយ៖
(ក) ដោយបានជូនដំណឹងដល់យើងខ្ញុំតាមរយៈសេចក្តីជូនដំណឹងពីខាងលោក-អ្នកមុនពេលចូលជាភាគីនៃកិច្ចព្រមព្រៀងនេះ រឺ
(ខ) ដោយបានបង្កើតឡើងជាក្រោយមកទៀត ដោយមានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីយើងខ្ញុំ។

"**ព្រឹត្តិការណ៍ដែលនឹងអាចក្លាយជាការរំលោភលើកិច្ចព្រមព្រៀង**" មានន័យថា ជាកាលៈទេសៈនានាដែលនឹងក្លាយទៅជាព្រឹត្តិការណ៍នៃការរំលោភ លើកិច្ចព្រមព្រៀង ដោយគ្រាន់តែការកន្លងផុតទៅនៃពេលវេលា រឺ ប្រសិនបើសេចក្តីជូនដំណឹងខ្លះត្រូវបានផ្តល់ជូនទៅលោក-អ្នក។

"**កាលបរិច្ឆេទត្រួតពិនិត្យឡើងវិញ**" មានន័យថា ជាកាលបរិច្ឆេទដែលបានបញ្ជាក់ ដូចមាននៅក្នុងលិខិតផ្តល់ឥណទាន។

"**កិច្ចធានា រឺ ការធានាកាតព្វកិច្ច**" មានន័យថាផលប្រយោជន៍ក្នុងទ្រព្យធានាដែលត្រូវបានផ្តល់ជូនយើងខ្ញុំចំពោះកាតព្វកិច្ចរបស់លោក-អ្នក (មិនថាក្រោម រឺ មិនក្រោមកិច្ចព្រមព្រៀងនេះ) និងដែលត្រូវបានផ្តល់ជូនដល់យើងខ្ញុំពីមុន រឺ នឹងត្រូវផ្តល់ជូនយើងខ្ញុំនៅពេលអនាគត។

"**ផលប្រយោជន៍ក្នុងទ្រព្យធានា រឺ សិទ្ធិប្រាតិភោគ**" មានន័យថា៖

(ក) សិទ្ធិណាមួយ រឺ ផលប្រយោជន៍ប្រភេទណាមួយ ដែលត្រូវបានផ្តល់ជូនតាមរបៀបនៃកិច្ចធានា ( ឧទាហរណ៍ រួមមាន កិច្ចសន្យាដាក់បញ្ចាំ (ហ៊ីប៉ូតែក) (Mortgage) ការដាក់បញ្ចាំហ៊ុន (Pledge) ការដាក់ទ្រព្យបញ្ចាំ (Antichrese) ការដាក់ធានា (Gage) សិទ្ធិឃាត់ទុក (Lien) ការដាក់បន្ទុក (Charge) រឺការផ្ទេរសិទ្ធិ )

(ខ) ការរៀបចំងទៀតណាមួយ (រួមទាំងការរៀបចំចាត់ចែងជាបុរិមា អាណត្តិព្យាបាលភាព ការធ្វើការទទួលទុកលើកម្មសិទ្ធិ រឺ ការរៀបចំអោយមានជាការទូទាត់កាត់កងណាមួយ) ដែលមានប្រសិទ្ធិភាពខាងពាណិជ្ជកម្មប្រហាក់ប្រហែលគ្នាដូចការផ្តល់កិច្ចធានា រឺ

(គ) ការធានា រឺ ការសងការខូចខាត។

"**អ្នកផ្តល់កិច្ចធានា**" មានន័យថា បុគ្គលដែលបានផ្តល់ជូន រឺ ផ្តល់ជូន រឺ នឹងផ្តល់ជូនទ្រព្យធានា និងរួមបញ្ចូលទាំង ប្រតិបត្តិករ អ្នកគ្រប់គ្រងទ្រព្យ សន្តតិជន អ្នកទទួលបានការផ្ទេរសិទ្ធិរបស់បុគ្គលនោះ។

"**ការដោះស្រាយបញ្ចប់**" មានន័យថា សកម្មភាពដែលយើងខ្ញុំធ្វើឡើងក្នុងនាមលោក-អ្នកដើម្បីទទួលបាន រឺ ជំរះចោលនូវទ្រព្យសកម្ម រឺ ទ្រព្យសម្បត្តិនានា។

"**កាលបរិច្ឆេទបញ្ចប់**" សំរាប់សំណុំឥណទានមានន័យថា៖

(ក) កាលបរិច្ឆេទបញ្ចប់នៃសំណុំឥណទានដែលមានចែងក្នុងលិខិតផ្តល់ឥណទាន រឺ

(ខ) ថ្ងៃដែលយើងខ្ញុំបញ្ចប់នូវកាតព្វកិច្ចរបស់យើងខ្ញុំ ទាក់ទងនឹងសំណុំឥណទានក្រោមកិច្ចព្រមព្រៀងនេះ។

"**ឯកសារប្រតិបត្តិការ**" មានន័យថា ឯកសារណាមួយដូចខាងក្រោម៖

(ក) លិខិតផ្តល់ឥណទានរបស់យើងខ្ញុំ

(ខ) លក្ខខណ្ឌទូទៅរបស់យើងខ្ញុំ

(គ) លក្ខខណ្ឌពិសេសណាមួយ សំរាប់សំណុំឥណទាននីមួយៗ

(ឃ) កិច្ចធានាទាំងឡាយ រឺ

(ង) ឯកសារចាំបាច់ដទៃទៀត ដែលមានទំនាក់ទំនងទៅនឹងកិច្ចព្រមព្រៀងនេះ ហើយក៏មានន័យថា ឯកសារណាមួយ រឺ កិច្ចព្រមព្រៀងទាំងឡាយណាដែលបំពេញបន្ថែម រឺ ធ្វើការកែប្រែចំនុចណាមួយ នៃចំនុចទាំងនេះ រឺ ជំនួសឯកសារទាំងនេះ។

"**យើងខ្ញុំ**" "**យើង**" "**ខ្ញុំ**" មានន័យថា ធនាគារ។

"**លោក-អ្នក**" មានន័យថា អតិថិជន។

***បញ្ញត្តិអំពីក្រុមហ៊ុន***

**(២)** សំរាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ៖

(ក) "**ក្រុមហ៊ុនបុត្រសម្ព័ន្ធ**" មានន័យថា ជាក្រុមហ៊ុន ដែលអតិថិជនធ្វើជាម្ចាស់លើដើមទុនជាងពាក់កណ្តាលដែលបានចុះបញ្ជីហើយពាក្យ "**ក្រុមហ៊ុនបុត្រសម្ព័ន្ធផ្តាច់មុខ**" មានន័យថា ក្រុមហ៊ុនដែលអតិថិជនធ្វើជាម្ចាស់លើដើមទុនចុះបញ្ជីទាំងអស់ និង

(ខ) "**ក្រុមហ៊ុនបុត្រសម្ព័ន្ធញ្ញាតិ**" មានន័យថា ក្រុមហ៊ុនដែលអតិថិជន រឺ ម្ចាស់ហ៊ុនរបស់អតិថិជនធ្វើជាម្ចាស់លើដើមទុន ៥០% ដែលបានចុះបញ្ជី។

***អតិថិជនច្រើនជាងមួយនាក់***

**(៣)** ប្រសិនបើអតិថិជនត្រូវបានផ្សំឡើងដោយបុគ្គលលើសពីមួយនាក់៖

(ក) ទំនួលខុសត្រូវរបស់បុគ្គលទាំងនោះក្រោមកិច្ចព្រមព្រៀងនេះ គឺរួមគ្នាផង និងទទួលខុសត្រូវចំពោះគ្នា និង រៀងៗខ្លួនផង (ទទួលខុសត្រូវដោយសាមគ្គីភាព) និង

(ខ) ការយោងទៅដល់ពាក្យ "លោក-អ្នក" រឺ "អតិថិជន" គឺរួមបញ្ចូលនូវការយោងទៅដល់បុគ្គលទាំងនោះ ម្នាក់ៗដាច់ពីគ្នា និងទៅដល់បុគ្គលទាំងនោះដែលមាន គ្នាពីរ រឺ ច្រើនអ្នកផងដែរ។

***ពាក្យ និង សំនួនសេចក្តី ដែលមានកំណត់នៅកន្លែងផ្សេង***

**(៤)** ទោះបីដូចមានក្នុងអនុប្រការ (១) ដល់ (៣) ពាក្យ និង សំនួនសេចក្តី ដែលត្រូវបានកំណត់និយមន័យនៅក្នុងលិខិតផ្តល់ឥណទាន រឺ នៅក្នុងលក្ខខណ្ឌពិសេសសំរាប់សំណុំឥណទាន គឺមានអត្ថន័យដូចអត្ថន័យដែលមានក្នុងលិខិតផ្តល់ឥណទាន រឺ លក្ខខណ្ឌពិសេសដែលពាក់ព័ន្ធ។

## ៣២.ចំនុចផ្សេងៗ

**(១)** កាតព្វកិច្ចណាមួយដែលលោក-អ្នកមានក្រោមកិច្ចព្រមព្រៀងនេះ ក្នុងការបង់ទូទាត់ដល់យើងខ្ញុំនូវប្រាក់ដែលជាថ្លៃចំណាយ រឺ ការទទួលខុសត្រូវរបស់លោក- អ្នក ចំពោះការខាតបង់ដែលយើងខ្ញុំអាចនឹងទទួលរង គឺជាកាតព្វកិច្ចបន្តទៅមុខ និងអនុវត្តទៅបានដោយមិនចំណុះ ហើយនឹងនៅតែបន្តទោះបីជាកិច្ចព្រមព្រៀងនេះត្រូវបានបញ្ចប់ក៏ដោយ។

**(២)** លោក-អ្នកយល់ព្រមថា ការសំរេចជាលាយលក្ខណ៍អក្សរដោយយើងខ្ញុំ អំពីទឹកប្រាក់ណាមួយដែលពាក់ព័ន្ធទៅនឹងកិច្ចព្រមព្រៀងនេះ (រួមទាំងការសំរេចពីទឹកប្រាក់ដែលលោក-អ្នកបានជំពាក់យើងខ្ញុំនៅពេលដោយឡែកណាមួយ) គឺជាការសំរេចយ៉ាងដាច់ស្រេច លើកលែងតែមានភាពល្អៀងបង្ហាញចេញមកច្បាស់។

(៣) ប្រសិនបើ បញ្ញត្តិណាមួយនៃកិច្ចព្រមព្រៀងនេះ មានលក្ខណៈមិនស្របច្បាប់ រឺ មិនអាចអោយគូភាគីអនុវត្តបាន តាមយុត្តាធិការណាមួយ នោះកិច្ចព្រមព្រៀងនេះ គឺត្រូវបានបកស្រាយដូច្នោះ ចំពោះតែគោលបំណងនៃយុត្តាធិការនោះប៉ុណ្ណោះ ដោយចាត់ទុកថា ពីមុនមកពុំដែលបានបញ្ចូលបញ្ញត្តិ ដែលខុសច្បាប់ រឺ ដែលអនុវត្តមិនកើតនោះ។

(៤) លោក-អ្នកមិនអាចធ្វើការផ្ទេរសិទ្ធិ រឺ កាតព្វកិច្ចណាមួយ របស់លោក-អ្នកក្រោមឯកសារប្រតិបត្តិការទេ លើកលែងតែយើងខ្ញុំបានយល់ព្រមជាលាយលក្ខណ៍អក្សរ។ យើងខ្ញុំអាច ផ្ទេរសិទ្ធិ រឺ កាតព្វកិច្ចណាមួយរបស់យើងខ្ញុំ ក្រោមឯកសារប្រតិបត្តិការបាន។

*យើងខ្ញុំអាចបង់ប្រាក់ឈ្នួលដល់ភ្នាក់ផ្តួចផ្តើម*

(៥) យើងខ្ញុំអាចបង់ប្រាក់ឈ្នួលដល់អ្នកផ្តួចផ្តើម រឺ ដើងសារ ដោយហេតុថា ឧទាហរណ៍ ពួកគេបានបញ្ជូនពាក្យស្នើសុំហិរញ្ញវត្ថុរបស់លោក-អ្នក មកដល់យើងខ្ញុំ។ អ្នកផ្តួចផ្តើម រឺ ដើងសារ មិនមែនជាភ្នាក់ងាររបស់យើងខ្ញុំទេ ប៉ុន្តែពួកគេចុះកិច្ចសន្យាឯករាជ្យជាមួយយើងខ្ញុំក្នុងការណែនាំបញ្ជូនឥណទាន និងជាកិច្ចតបស្នង ដែលត្រូវតែមានការបង់ប្រាក់ឈ្នួល។

*របាយការណ៍*

(៦) យើងខ្ញុំនឹងចេញរបាយការណ៍ ដូចដែលបានព្រមព្រៀងរវាងលោក-អ្នកជាមួយយើងខ្ញុំ ទាក់ទងទៅនឹងគណនីទាំងឡាយ ដែលជាទូទៅយើងខ្ញុំនឹងចេញរបាយការណ៍ឱ្យ។ ការដាក់ប្រាក់ រឺ ការទូទាត់សង ដែលបានធ្វើឡើងទៅលើសំណុំឥណទានរបស់លោក-អ្នក នៅថ្ងៃចុងក្រោយនៃអំឡុងពេលរបស់របាយការណ៍ អាចនឹងមិនបង្ហាញនៅលើរបាយការណ៍សំរាប់អំឡុងពេលនោះឡើយ។ តែទោះជាយ៉ាងណាក៏ដោយ ការដាក់ប្រាក់ រឺ ការទូទាត់សងទាំងឡាយនេះ នឹងត្រូវបានបង្ហាញនៅក្នុងរបាយការណ៍បន្ទាប់របស់លោក-អ្នក ព្រមជាមួយនឹងលិខិតមួយ ដែលបញ្ជាក់ពីកាលបរិច្ឆេទមានប្រសិទ្ធិភាពរបស់ការដាក់ប្រាក់ រឺ ការទូទាត់សងនោះ។

*ការផ្ទៀងផ្ទាត់គណនី*

(៧) លោក-អ្នកត្រូវត្រួតពិនិត្យឡើងវិញ និងធ្វើការផ្ទៀងផ្ទាត់ កំណត់ត្រានានារបស់លោក-អ្នក ដែលពាក់ព័ន្ធនឹងគណនីនីមួយៗ ដែលមានជាមួយនឹងយើងខ្ញុំក្នុងរយៈពេល៧ថ្ងៃ (ដូចមានតាមការរៀបចំឡើងរវាងលោក-អ្នក ជាមួយនឹងយើងខ្ញុំ) នៅដំណាច់ខែនីមួយៗតាមប្រតិទិន ហើយត្រូវជូនដំណឹងដល់យើងខ្ញុំភ្លាម ប្រសិនបើ៖

(ក) មានការមិនបានបញ្ចូល រឺ មានការចុះឥណពន្ធខុសណាមួយ កើតឡើងចំពោះគណនី រឺ

(ខ) មានប្រតិបត្តិការដែលគ្មានការអនុញ្ញាតណាមួយ ដែលបានធ្វើឡើងចំពោះគណនីណាមួយ។

លើកលែងតែក្នុងវិសាលភាពដូចតទៅនេះ៖

(១) លោក-អ្នកបានជូនដំណឹងដល់ធនាគារ ដេ គ្រាស់ រ៉ូយ៉ាល់ ស្របតាម ប្រការ ៣២(៧) នេះ

(២) មានកំរៃផ្សេងៗរបស់ធនាគារណាមួយ ដែលត្រូវបានចុះឥណពន្ធ រឺ ដែលត្រូវបានចុះជាឥណទានមិនត្រឹមត្រូវដោយ ធនាគារ ដេ គ្រាស់ រ៉ូយ៉ាល់ នោះកំណត់ត្រាចូលនៅក្នុងរបាយការណ៍គណនីទាំងនោះ នឹងត្រូវចាត់ទុកថាត្រឹមត្រូវក្រោយរយៈពេល ៧ ថ្ងៃ ដោយមិនចាំបាច់ត្រូវរកភស្តុតាងបន្ថែមមកបញ្ជាក់ថា កំណត់ត្រាចូលទាំងនោះត្រឹមត្រូវ និង ពេញលេញឡើយ ហើយយើងខ្ញុំត្រូវរួចផុតពីបណ្តឹងទាមទារទាំងអស់ ទាក់ទងនឹងគណនីនោះ។

*ការអាក់ខានក្នុងការផ្តល់សេវា*

(៨) ការអាក់ខាន គឺជាពេលដែលសេវាពុំអាចទទួលបានជាបណ្តោះអាសន្ន រឺ នៅពេលដែលប្រព័ន្ធ រឺ ឧបករណ៍ពុំអាចដំណើរការតាមធម្មតា រឺ តាមលក្ខណៈមួយដែលគួរឱ្យពេញចិត្ត។ យើងខ្ញុំនឹងទទួលខុសត្រូវចំពោះតែការខាតបង់ រឺ ការខូចខាតណាដែលបានទទួលរងដោយសារតែការអាក់ខាន ក្នុងករណីដែលការអាក់ខាននោះ ត្រូវបានបណ្តាលមកពី ព្រឹត្តិការណ៍ដែលស្ថិតក្នុងការគ្រប់គ្រងយ៉ាងសមហេតុផលរបស់យើងខ្ញុំ។ យើងខ្ញុំនឹងមិនទទួលខុសត្រូវចំពោះការខាតបង់ រឺ ការខូចខាតបន្ថែម ដែលបណ្តាលមកពីអាក់ខាននេះទេ។ ការបដិសេធទទួលខុសត្រូវនេះ គឺជាការបន្ថែម តែមិនមែនជាការដាក់កម្រិតទៅលើបញ្ញត្តិឯទៀតណាមួយ ដែលមាននៅក្នុងប្រការ និងលក្ខខណ្ឌទាំងនេះ ដែលបានកម្រិតទៅលើទំនួលខុសត្រូវរបស់ធនាគារឡើយ។

*ការប្រឆាំងនឹងការសំអាតប្រាក់*

(៩) លោក-អ្នកយល់ព្រមឱ្យយើងខ្ញុំអាចពន្យាពេល រាំងខ្ទប់ រឺ បដិសេធមិនធ្វើការទូទាត់ណាមួយ ប្រសិនបើយើងខ្ញុំជឿជាក់ ដោយមានហេតុផល ត្រឹមត្រូវថា ការទូទាត់នោះ អាចល្មើសច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា រឺ ប្រទេសឯទៀតណាមួយ រឺ អាចពាក់ព័ន្ធដោយផ្ទាល់ រឺ ប្រយោល ទៅនឹងទង្វើខុសច្បាប់ ហើយយើងខ្ញុំនឹងពុំទទួលខុសត្រូវចំពោះលោក-អ្នក ប្រសិនបើយើងខ្ញុំធ្វើដូច្នេះ។ លោក-អ្នកយល់ព្រមផ្តល់ជូននូវព័ត៌មានទាំងអស់មកដល់យើងខ្ញុំ តាមដែលយើងខ្ញុំត្រូវការ ដោយអនុលោមស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា រឺ ប្រទេសឯទៀតណាមួយ យ៉ាងសមហេតុសមផល។ លោក-អ្នកយល់ព្រមថា យើងខ្ញុំអាចបើកចំហរព័ត៌មានដែលលោក-អ្នកបានផ្តល់មកដល់យើងខ្ញុំ និង/រឺ ធ្វើការរាយការណ៍ដល់ភ្នាក់ងារអនុវត្តច្បាប់ រឺ និយ័តករ កាលណាមានការតំរូវពីច្បាប់ណាមួយនៃព្រះរាជាណាចក្រកម្ពុជា រឺ ប្រទេសឯទៀតណាមួយ។ លោក-អ្នកប្រកាស និងធានា ចំពោះយើងខ្ញុំថា ការទូទាត់ប្រាក់ដែលយើងខ្ញុំធ្វើស្របតាមសេចក្តីណែនាំរបស់លោក-អ្នក នឹងមិនល្មើសច្បាប់ណាមួយរបស់ព្រះរាជាណាចក្រកម្ពុជា រឺ ប្រទេសផ្សេងឯទៀតណាមួយឡើយ។

*ការដកប្រើប្រាស់ រឺ ការប្រតិបត្តិលើសំណុំឥណទាន*

(១០) ច្បាប់តំរូវឱ្យធនាគារត្រួតពិនិត្យអត្តសញ្ញាណម្ចាស់គណនី និង ហត្ថលេខី ទាំងអស់អោយបានត្រឹមត្រូវ។ សំណុំឥណទានខ្លះអាច នឹងត្រូវបានផ្តល់ជូនដោយមិនមានការពាក់ព័ន្ធនឹងគណនី។ សំរាប់គោលបំណងនៃប្រការនេះ សំណុំឥណទានដែលត្រូវបានផ្តល់ ជូនដោយគ្មានគណនីពាក់ព័ន្ធ នឹងត្រូវបានចាត់ទុកថាជា គណនី។ មុនពេលដែលលោក-អ្នកដកប្រើប្រាស់ រឺ ប្រតិបត្តិ លើសំណុំឥណទាន យើងខ្ញុំនឹងតំរូវឱ្យលោក-អ្នកផ្តល់នូវឯកសារ រឺ អត្តសញ្ញាណ ដើម្បីផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់លោក-អ្នក ប្រសិនបើលោក-អ្នកពុំទាន់ត្រូវបានធ្វើអត្តសញ្ញាណដោយយើងខ្ញុំពីមុនមក។

*សិទ្ធិក្នុងការដកលិខិតផ្តល់ឥណទាន*

(១១) យើងខ្ញុំអាចដកសំណើរបស់យើងខ្ញុំក្រោមលិខិតផ្តល់ឥណទានណាមួយ នៅពេលណាមួយ មុនពេលដែលលោក-អ្នកផ្តល់ស្វីការ លើការផ្តល់ជូននោះ ប្រសិនបើ យើងខ្ញុំដឹងថាមានអ្វីមួយ ដែលតាមការវិនិច្ឆ័យរបស់យើងខ្ញុំ បណ្តាលឱ្យមានការកែប្រែជាអវិជ្ជមានណាមួយ លើមូលដ្ឋានដែលយើងខ្ញុំបានយកជាបង្អែកក្នុងការផ្តល់លិខិតផ្តល់ឥណទានរបស់យើងខ្ញុំ ។

## ៣៣. ភាពមិនស៊ីសង្វាក់គ្នា

(១) ប្រសិនបើមានភាពមិនស៊ីសង្វាក់គ្នារវាងលិខិតផ្តល់ឥណទាន និង លក្ខខណ្ឌទូទៅទាំងនេះ រឺ លក្ខខណ្ឌពិសេស សំរាប់សំណុំឥណទានមួយ នោះលិខិតផ្តល់ឥណទាន ត្រូវយកជាបានការ។

(២) ប្រសិនបើមានភាពមិនស៊ីសង្វាក់គ្នារវាងលក្ខខណ្ឌទូទៅទាំងនេះ និងលក្ខខណ្ឌពិសេសសំរាប់សំណុំឥណទានមួយ នោះលក្ខខណ្ឌពិសេសត្រូវយកជាបានការ។

(៣) ប្រសិនបើមានភាពមិនស៊ីសង្វាក់គ្នារវាង កិច្ចព្រមព្រៀងនេះ ជាមួយនឹងកិច្ចធានា នោះកិច្ចព្រមព្រៀងនេះត្រូវយកជាបានការ។

## ៣៤. បញ្ញត្តិស្តីពីការបកស្រាយផ្សេងទៀត

(១) ឯកត្តជន រឺ បុគ្គល ក៏អាច សំដៅដល់ ក្រុមហ៊ុន ហើយនិងផ្ទុយត្រឡប់មកវិញ។

(២) ឯកវចនៈ រួមបញ្ចូលនូវ ពហុវចនៈ ហើយនិងផ្ទុយត្រឡប់មកវិញ។

(៣) កិច្ចព្រមព្រៀង ឯកសារ រឺ ច្បាប់ គឺជាការសំដៅដល់ កិច្ចព្រមព្រៀង ឯកសារ រឺ ច្បាប់ (ហើយប្រសិនបើអាចគឺបញ្ញត្តិណាមួយរបស់វា) ដូចដែលត្រូវបានកែប្រែ កត់ចំណាំ បំពេញបន្ថែម រឺ ដាក់ជំនួសសំរាប់ពេលបច្ចុប្បន្ននេះ។
ឧទាហរណ៍: កាលណាលិខិតផ្តល់ឥណទានដើមរបស់យើងខ្ញុំ ត្រូវបានធ្វើអោយមានការផ្លាស់ប្តូរក្រោយមកទៀតនោះ ការយោងនៅក្នុងឯកសារប្រតិបត្តិការណាមួយទៅលើលិខិតផ្តល់ឥណទាននោះ មានន័យថាជាការយោងដល់លិខិតផ្តល់ឥណទានដែលមានការកែប្រែនោះ។

(៤) តារាងដែលភ្ជាប់នឹងឯកសារ គឺជាផ្នែកមួយនៃឯកសារ។

(៥) ផ្នែក ប្រការ ខ ចំណងជើង និងកំណត់សំគាល់នានា មិនមែនជាផ្នែកនៃកិច្ចព្រមព្រៀងនេះទេ គឺគ្រាន់តែសំរាប់ជួយសំរួលអោយមានភាពងាយស្រួលប៉ុណ្ណោះ។

(៦) កាលណាសំនួនសេចក្តីត្រូវបានកំណត់និយមន័យ នោះផ្នែកឯទៀតនៃស័ព្ទ រឺ ទំរង់វេយ្យាករណ៍នៃសំនួនសេចក្តីនោះ ត្រូវតែមានអត្ថន័យឆ្លើយតបគ្នា។

ធនាគារ ដេ ត្រាស់ រ៉ូយ៉ាល់

J Trust Royal Bank